00615868

លេខ/No: D427/2/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-អ.ប.ជ(១៤៥) |
| ភាគីដាក់ឯកសារ: | សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ |
| ដាក់ជូន: | អង្គបុរេជំនុំជម្រះ |
| ភាសាដើម: | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១០ |

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 21 / 10 / 2010
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ / Public CR

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ**

---

ដាក់ដោយ៖

**សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ៖**

ផាត់ ពៅស៊ាង

Diana ELLIS, QC

ផ្ញើជូន៖

**ចៅក្រមអង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន ប្រធាន

ចៅក្រម ហួត វុទ្ធី

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ធុល

ចៅក្រម Katinka LAHUIS

ចៅក្រម ប៉ែន ពេជ្រសាលី

លេខ/No: D427/2/1

០០២/១៩-០៩-២០០៧-អវតក-កសចស-អបជ(១៤៥)

---

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី និង**

**ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានអ្នកតំណាង**

# មាតិកា


I សេចក្តីផ្តើម និង សំណើសុំ 2

II ភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ 2

III ការជំទាស់តវ៉ានឹងយុត្តាធិការ 4

3.1 សេចក្តីផ្តើម 4

3.2 គោលការណ៍នៃគ្មានបទល្មើសបើគ្មានច្បាប់ចែង 4

3.3 ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ 5

3.3.1 ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនមែនជាបទឧក្រិដ្ឋផ្អែកតាមច្បាប់ជាតិរបស់កម្ពុជា 6

3.3.2 ច្បាប់បង្កើត អវតក មិនអាចបង្កើតច្បាប់ថ្មី និងអនុវត្តច្បាប់នោះឲ្យមានប្រតិសកម្មបាន 7

3.3.3 បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនត្រូវបានអនុវត្តផ្ទាល់នៅ អវតក 8

3.3.4 ដើមបណ្តឹងឧទ្ធរណ៍មិនបានព្យាករណ៍ទុកជាមុន និងមិនអាចដឹងបានពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ 15

3.4 ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ 17

3.4.1 ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនបង្កើតបានជាបទល្មើសព្រហ្មទណ្ឌនៅក្នុងច្បាប់ 18

3.4.2 ច្បាប់ អវតក មិនអាចបង្កើតច្បាប់ថ្មី និងអនុវត្តច្បាប់ជាប្រតិសកម្មបានទេ 18

3.4.3 ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជា "បទឧក្រិដ្ឋកម្មអន្តរជាតិ" មិនអាចយកមកអនុវត្តដោយផ្ទាល់នៅ អវតក បានទេ 19

3.5 ការរំលោភបំពានធ្ងន់ធ្ងរ 28

3.5.1 ការរំលោភបំពានធ្ងន់ធ្ងរមិនបានបង្កើតជាផ្នែកមួយនៃច្បាប់កម្ពុជាទេ 30

3.5.2 ច្បាប់បង្កើត អវតក មិនអាចបង្កើតច្បាប់ថ្មីបានទេ ហើយអនុវត្តច្បាប់ថ្មីនោះដោយប្រតិសកម្មបានទេ 31

3.5.3 គ្មានការអនុវត្តដោយផ្ទាល់នូវការរំលោភបំពានធ្ងន់ធ្ងរជាបទឧក្រិដ្ឋកម្មអន្តរជាតិ 31

3.6 បទឧក្រិដ្ឋកម្មជាតិ 32

3.7 បទសហឧក្រិដ្ឋកម្មរួម 34

3.8 ការទទួលខុសត្រូវរបស់ថ្នាក់លើ 34

3.8.1 ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ 35

3.8.2 ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចអនុវត្តទៅបានចំពោះតែឧក្រិដ្ឋកម្មសង្គ្រាម 38

3.8.1 អនុវត្តដោយមានកម្រិតលើការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះជនស៊ីវិល 39

3.9 សេចក្តីសនិដ្ឋាន 40

IV ការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ 40

4.1 ដីកាដំណោះស្រាយពុំមានសម្អាងហេតុគ្រប់គ្រាន់ គឺជាការធ្វើឡើងតាមទំនើងចិត្ត 40

4.2 ការរកឃើញអង្គច្បាប់មិនអាចចម្លងយកមកដាក់ដោយមិនផ្តល់សម្អាងហេតុឲ្យបាន 42

4.3 ដីកាដំណោះស្រាយមួយផ្នែកត្រូវចាត់ទុកជាអសាឥតការ 43

V សំណើសុំឲ្យមានសវនាការជាសាធារណៈ 44

VI សេចក្តីសន្និដ្ឋាន 44

## I. សេចក្តីផ្តើម និងសំណើសុំ

១. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) បានដាក់ដីកាដំណោះស្រាយរបស់ខ្លួន ដោយចោទប្រកាន់ អ្នកស្រី អៀង ធីរិទ្ធ, ម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះបទឧក្រិដ្ឋជាតិ និងអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត [1] ។ ហេតុដូច្នេះ មេធាវីការពារក្តីរបស់ អ្នកស្រី អៀង ធីរិទ្ធ (ដើមបណ្តឹងឧទ្ធរណ៍) សូមដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយនេះ។

## II. ការទទួលយកបាននូវបណ្តឹងឧទ្ធរណ៍នេះ

២. វិធាន ៦៧(៣)(ក) ចែងថា សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាលើកលែងចោទប្រកាន់ប្រសិនបើអំពើដែលចោទប្រកាន់ មិនរាប់ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។ វិធាន ៦៧(៥) ដែលមានភាពពាក់ព័ន្ធ បានចែងថា"ដីកាដំណោះស្រាយនេះបើកផ្លូវប្តឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤"។ វិធាន ៧៤(៣)(ក) ចែងថា ដើមបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដូចជា "ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"។

៣. នៅក្នុង "សាលដីកា[របស់អង្គបុរេជំនុំជម្រះ (អ.ប.ជ)] លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ"[2] អង្គបុរេជំនុំជម្រះបានសម្រេចថា សំណើធ្វើឡើង

---

[1] ដីកាដំណោះស្រាយ ក.ស.ច.ស ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 (ដីកាដំណោះស្រាយ)។ ឯកសារនេះត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។

[2] អង្គបុរេជំនុំជម្រះ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D345/5/11។

ឆាប់រហ័សពេក ហើយ "ប្រសិនបើដីកាដំណោះស្រាយបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក ទៅលើការទទួលខុសត្រូវរបស់ថ្នាក់លើនោះ ជនត្រូវចោទអាចពិចារណាអំពីអានុភាពវិធាន ៦៧(៥) និងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង នៅពេលអានវិធានទាំងពីរនេះរួមគ្នា"។[3] ហេតុដូចនេះ មេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះមេត្តាអនុញ្ញាតឱ្យមេធាវីការពារក្តីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនេះ ដោយផ្អែកលើមូលដ្ឋានយុត្តាធិការ។

៤. នៅក្នុងសាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការបំពារបំពានលើនីតិវិធី អង្គបុរេជំនុំជម្រះបានសម្រេចបន្ថែមថា បណ្តឹងឧទ្ធរណ៍អាចធ្វើឡើងផ្អែកតាមសិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ក្រោមវិធាន២១ នៃវិធានផ្ទៃក្នុង[4]។ អ.ប.ជ សម្រេចនៅក្នុងកថាខណ្ឌ១៤ថា៖

> ការពិចារណាលើសលុបនៅក្នុងរាល់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីទាំងនេះ ដូចមានចែងនៅក្នុងវិធាន២១(១)(ក) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍លើកឡើងនូវបញ្ហាធ្ងន់ធ្ងរមួយនៃភាពយុត្តិធម៌ ហេតុដូច្នេះអង្គបុរេជំនុំជម្រះមានយុត្តាធិការក្នុងការពិចារណាដោះស្រាយបណ្តឹងនេះ។

៥. ដូចនេះ មេធាវីការពារក្តីលើកឡើងថា បណ្តឹងឧទ្ធរណ៍នេះ អាចទទួលយកបានដោយផ្អែកលើមូលដ្ឋានចំនួនពីរ ពោលគឺមិនមានយុត្តាធិការ និងការបំពារបំពានលើសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ ដោយសារតែមេធាវីការពារក្តី ត្រូវបានកំណត់មិនឱ្យប្តឹងឧទ្ធរណ៍ផ្អែកលើមូលដ្ឋានផ្សេងទៀត និងដោយពិចារណាលើការកំណត់ទាក់ទិននឹងទំហំនៃបណ្តឹងឧទ្ធរណ៍នេះ មេធាវី ការពារក្តី

---

[3] ដូចជើងទំព័រខាងលើ កថាខណ្ឌ១១។

[4] អ.ប.ជ, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី (D264/1), ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6។

រក្សាសិទ្ធិក្នុងការលើកឡើងទឡ្ហីករណ៍យុត្តាធិការបន្ថែមក្នុងអំឡុងពេលសវនាការបឋម និងរក្សាសិទ្ធិក្នុងការលើកឡើងបន្ថែមនូវភាពខ្វះខាតរបស់ដីកាដំណោះស្រាយនៅឱកាសក្រោយៗទៀត។

## III. ការតវ៉ាទាក់ទិននឹងយុត្តាធិការ

### ៣.១ សេចក្តីផ្តើម

៦. មេធាវីការពារក្តី លើកឡើងថា អ.វ.ត.ក មិនមានយុត្តាធិការកាត់សេចក្តីដើមបណ្តឹងឧទ្ធរណ៍ចំពោះបទឧក្រិដ្ឋដូចខាងក្រោម៖

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (ផ្នែក ៤.៣)
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ផ្នែក ៤.៤)
- ការបំពារបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវ (ផ្នែក ៤.៥) និង
- បទឧក្រិដ្ឋផ្នែកតាមច្បាប់ជាតិ (ផ្នែក ៥.៦)

បន្ថែមពីលើនេះ មេធាវីការពារក្តី លើកឡើងថា អ.វ.ត.ក មិនមានយុត្តាធិការកាត់សេចក្តីដើមបណ្តឹងឧទ្ធរណ៍ផ្អែកលើមូលដ្ឋាននៃទម្រង់ទទួលខុសត្រូវដូចខាងក្រោម៖

- សហឧក្រិដ្ឋកម្មរួម (ផ្នែក ៥.៧) និង
- ការទទួលខុសត្រូវរបស់ថ្នាក់លើ (ផ្នែក ៥.៨)

### ៣.២ គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង

៧. ទីមួយ មេធាវីការពារក្តីលើកឡើងថា គោលការណ៍*គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* ហាមឃាត់មិនឲ្យកាត់សេចក្តីលើបទឧក្រិដ្ឋមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវ ដូចមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៨. មាត្រា ៣៣(២) នៃច្បាប់ អ.វ.ត.ក ចែងថា គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬអកម្ម ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅខណៈពេលប្រព្រឹត្តនោះទេ។

៩. មាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ចែងថា៖

ច្បាប់ព្រហ្មទណ្ឌ គ្មានអានុភាពជាប្រតិសកម្មទេ គឺថា បទល្មើសណា បានប្រព្រឹត្តមុនបទបញ្ញត្តិរបស់ច្បាប់ បទល្មើសនោះ មិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ។ ប៉ុន្តែបើច្បាប់ថ្មីលុបចោលបទល្មើសណាមួយ ឬសម្រាលទោសរបស់បទល្មើសណាមួយវិញ បទល្មើសដែលបានប្រព្រឹត្តមុនច្បាប់ថ្មី នេះ ត្រូវបានរួចផុតពីទោស ឬក៏ទោសនោះ ត្រូវបានស្រាលតាមច្បាប់ថ្មីនេះដែរកុំឲ្យតែបទល្មើសនោះ បានទទួលការផ្តន្ទាជាស្ថាពររួចអស់ទៅហើយ។

១០. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[5] ចែងនៅក្នុងមាត្រា ១៥(១)ថា៖

គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។

១១. បន្ថែមពីលើនេះ មាត្រា១៥(២) នៃICCPR ចែងថា "គ្មានបញ្ញត្តិណាមួយក្នុមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ"។

## ៣.៣ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

១២. មាត្រា៤ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក (ច្បាប់ អ.វ.ត.ក) ចែងថា "[អ.វ.ត.ក] មានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩"។ មាត្រា ៤ បានកំណត់និយមន័យ "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ដូចខាងក្រោម៖

[5] កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, បានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិសេចក្តីសម្រេចចិត្តលេខ២២00 A(XXI) ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។

អំពើប្រល័យពូជសាសន៍ដែលគ្មានអាជ្ញាយុកាល គឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោមហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា៖

- ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

- ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម

- ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក។

- ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតដល់ទារក។

-ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត។

១៣. ច្បាប់ អ.វ.ត.ក បានប្រើប្រាស់និយមន័យ "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ដូចគ្នានឹងនិយមន័យដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[6]។

១៤. មេធាវីការពារក្តី លើកឡើងថា អ.វ.ត.ក មិនមានយុត្តាធិការដើម្បីកាត់សេចក្តីដីមបណ្តឹងឧទ្ធរណ៍ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ។ ការកាត់សេចក្តីលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងរំលោភលើគោលការណ៍ជាសារវន្ត *គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង*។

## ៣.៣.១ <u>ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនមែនជាបទឧក្រិដ្ឋផ្នែកតាមច្បាប់ជាតិរបស់ប្រទេស កម្ពុជាទេ</u>

១៥. មាត្រា៣៣(២)(ថ្មី) នៃច្បាប់ អ.វ.ត.ក ដែលបានយោងតាម មាត្រា ១៥ នៃ នៃICCPR បានចែងយ៉ាងច្បាស់ថា ដើមបណ្តឹងឧទ្ធរណ៍ មិនអាចត្រូវជាប់ ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬអកម្ម ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ នៅខណៈពេលដែលបានប្រព្រឹត្តិអំពើនោះ។

---

[6] អនុសញ្ញាស្តីអំពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍, បានអនុម័តដោយសេចក្តីសម្រេចចិត្តលេខ២៦០ (III) A នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨, ចូលជាធរមាននៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៥១, មាត្រា២និង៣។

១៦. មេធាវីការពារក្តី លើកឡើងថា ដើមបណ្តឹងឧទ្ធរណ៍មិនអាចត្រូវបានកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ ដោយសារតែឧក្រិដ្ឋកម្មនេះ មិនមែនជាបទឧក្រិដ្ឋផ្អែកតាមច្បាប់ជាតិ នៅពេលដែលប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការថាជាក្រមព្រហ្មទណ្ឌនៅជាធរមានក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ [7] មិនមានចែងបទប្បញ្ញត្តិណាមួយកំណត់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ថាជាបទឧក្រិដ្ឋនោះទេ។

១៧. ហេតុដូច្នេះ ការកាត់សេចក្តីដើមបណ្តឹងឧទ្ធរណ៍ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ នឹងបំពារបំពានលើគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង ដែលអ.វ.ត.ក ត្រូវគោរពតាមគោលការណ៍នេះ។[8]

## ៣.៣.២ ច្បាប់ អ.វ.ត.ក មិនអាចបង្កើតច្បាប់ថ្មី និងអនុវត្តច្បាប់នោះឱ្យមានប្រតិសកម្មនោះទេ

១៨. សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា "ដើម្បីអាចឱ្យអំពើមួយត្រូវចាត់ចូលជាបទល្មើសនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិក្នុងពេលដែលអំពើនោះកើតឡើងនោះទេ នោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវចែងអំពី [...]"។[9] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើកឡើងថា ច្បាប់អន្តរជាតិត្រូវបានយកមកអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជា ចំពោះពេលវេលាពាក់ព័ន្ធ ដោយសារតែ "មាត្រា១ និងមាត្រា២ និងមាត្រា២៩(ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក បានដាក់បញ្ចូលក្នុងច្បាប់កម្ពុជានូវការរំលោភបំពានច្បាប់អន្តរជាតិមួយចំនួនដែលត្រូវឋិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ [...])"។[10]

---

[7] អ.ជ.ស.ជ, ការជម្រាបជូនអំពីក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងសំណើសុំផ្តល់ការបញ្ជាក់លើក្រមផ្លូវការ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២00៩។

[8] សូមមើលច្បាប់ស្តីពីការបង្កើត អវតក មាត្រា៣៣(២) ដែលយោងទៅមាត្រា១៥ របស់ ICCPR។

[9] ដីកាដំណោះស្រាយ កថាខណ្ឌ១៣0២។

[10] ដីកាដំណោះស្រាយ កថាខណ្ឌ១៣0៤។

១៩. មេធាវីការពារក្តី លើកឡើងថា សហចៅក្រមស៊ើបអង្កេតបានបកស្រាយច្បាប់ អ.វ.ត.ក មិនត្រឹមត្រូវ តាមរបៀបដែលថា ច្បាប់ អ.វ.ត.ក មានបំណងបង្កើតច្បាប់ព្រហ្មទណ្ឌថ្មី និងអនុវត្តច្បាប់នោះឲ្យមានប្រតិសកម្មទៅលើអំពើដែលរងការចោទប្រកាន់ថាត្រូវបានប្រព្រឹត្តកាលពី៣០ឆ្នាំមុន។

២០. ច្បាប់ អ.វ.ត.ក មិនអាចបង្កើតច្បាប់ព្រហ្មទណ្ឌសារធាតុទេ។ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ត្រូវបានបង្កើតឡើងដើម្បី "កំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា"[11] និងដើម្បី "វិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់[...] និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់" ដែលបានប្រព្រឹត្តិនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ [12] ។ ច្បាប់ អ.វ.ត.ក មិនបានបង្កើតនូវវិធានសារធាតុនៃច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែគ្រាន់តែចែងអំពីនិយមន័យរបស់បទឧក្រិដ្ឋទាំងឡាយដែលអ.វ.ត.កមានយុត្តាធិការ។

២១. បន្ថែមពីលើនេះ ច្បាប់ អ.វ.ត.ក មិនអាចអនុវត្តច្បាប់ព្រហ្មទណ្ឌឲ្យមានប្រតិសកម្មនោះទេ។ មេធាវីការពារក្តី រំឭកឡើងវិញថា "ចំណុចសំខាន់និងសមហេតុផលនៃទ្រឹស្តីនីត្យានុកូលភាពតឹងរ៉ឹងគឺថា វិធានព្រហ្មទណ្ឌមិនអាចអនុវត្តចំពោះអំពើ ឬការប្រព្រឹត្តិដែលបានកើតឡើងមុនពេលអនុម័តវិធាន បែបនោះទេ"។ [13] កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ផ្តល់សមត្ថកិច្ចឲ្យ អ.វ.ត.ក អនុវត្តច្បាប់ជាធរមានដើម្បីកាត់សេចក្តីបទល្មើសនានាដែលត្រូវបានប្រព្រឹត្តឡើងនៅពេលពាក់ព័ន្ធ ប៉ុន្តែមិនមែនឲ្យអនុវត្តច្បាប់ថ្មីឲ្យមានប្រតិសកម្មនោះទេ។

### ៣.៣.៣ បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនត្រូវបានអនុវត្តផ្ទាល់នៅ អ.វ.ត.ក ទេ

[11] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការផ្តន្ទាទោសបទល្មើសដែលបានប្រព្រឹត្តនៅក្នុងកំឡុងនៃកម្ពុជាប្រជាធិបតេយ្យនៅក្រោមច្បាប់កម្ពុជាចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២00៣ មាត្រា១។

[12] សូមមើលច្បាប់ស្តីពីការបង្កើត អវតក, មាត្រា១។

[13] Antonio Cassese, *International Criminal Law* (2003), ទំព័រ១៤៧។

២២. មេធាវីការពារក្ដីលើកឡើងថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនអាចអនុវត្តផ្ទាល់នៅ អ.វ.ត.ក ទេ ហេតុដូចនេះ ដើមបណ្ដឹងឧទ្ធរណ៍មិនអាចត្រូវបានកាត់សេចក្ដីដោយផ្អែកលើមូលដ្ឋាននេះទេ។

*អ.វ.ត.ក មិនមែនជា តុលាការ "អន្តរជាតិ" ដែលច្បាប់អន្តរជាតិអាចអនុវត្តផ្ទាល់នោះទេ។*

២៣. សហចៅក្រមស៊ើបអង្កេត បានលើកឡើងថា "បញ្ហាដែលថា តើ អ.វ.ត.ក ជាស្ថាប័នយុត្តាធិការជាតិ ឬអន្តរជាតិ មិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនេះនោះទេ"[14]។ ផ្ទុយមកវិញ មេធាវីការពារក្ដីលើកឡើងថា បញ្ហាដែលថា តើ អ.វ.ត.ក ជាស្ថាប័នជាតិ ឬអន្តរជាតិ គឺជាបញ្ហាសំខាន់ នៅពេលសម្រេចលើយុត្តាធិការរបស់ អ.វ.ត.ក។

២៤. អ.វ.ត.ក មានលក្ខណៈខុសគ្នាពីតុលាការយូហ្គោស្លាវី (ICTY) និងតុលាការរ៉្វាន់ដា (ICTR)។ តុលាការICTY និងតុលាការICTR គឺជាស្ថាប័ន*មិនអចិន្ត្រៃយ៍* បង្កើតឡើងជា "តុលាការអន្តរជាតិ" ដោយសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ។ តុលាការទាំងពីរ ត្រូវបានតម្រូវឱ្យកាត់សេចក្ដីជនទាំងឡាយពីបទល្មើសអន្តរជាតិ ដូចនេះតុលាការទាំងពីរនេះ ជាប់កាតព្វកិច្ចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ។[15] ចៅក្រមរបស់តុលាការ ICTY និងតុលាការ ICTR ត្រូវធានាថា ច្បាប់ពាក់ព័ន្ធនានា ត្រូវបានទទួលស្គាល់ថាជាច្បាប់ព្រហ្មទណ្ឌផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងធានាថា ច្បាប់ទាំងនេះ ត្រូវបានកំណត់និយមន័យគ្រប់គ្រាន់ក្រោមអង្គច្បាប់នៃច្បាប់ទំនៀមទម្លាប់នោះ[16]។ និយាយម្យ៉ាងវិញទៀត តុលាការ*មិនអចិន្ត្រៃយ៍*នេះ មិនមានយុត្តាធិការលើ

---

[14] ដីកាដំណោះស្រាយ កថាខណ្ឌ១៣០១។

[15] សូមមើល *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Hadzihasanovic និងអ្នកផ្សេងទៀត* សាលដីកាលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំប្រឆាំងនឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់មេបញ្ជាការ, សំណុំរឿងលេខ IT-01-47-AR72,ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២00៣, កថាខណ្ឌ៣៥, ៤៤-៤៦ និង ៥៥។

[16] សូមមើល *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Vasiljevic*, សាលក្រម, សំណុំរឿងលេខ IT-98-32-T, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២00២, កថាខណ្ឌ២០២។ សូមមើល *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Ojdanic*, សាលដីកាលើញត្តិរបស់ Dragoljub Ojdanic ប្រឆាំងនឹងយុត្តាធិការ – *សហឧក្រិដ្ឋកម្មរួម*, សំណុំរឿងលេខ IT-99-37-AR72, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២00៣, កថាខណ្ឌ៩,

00615880



ការរំលោភបំពានច្បាប់សន្ធិសញ្ញា ឬការរំលោភបំពានលើច្បាប់ជាតិ លុះត្រាតែច្បាប់ទំនៀមទម្លាប់ ឬច្បាប់ជាតិទាំងនោះ បានក្លាយជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[17]។

២៥. អ.វ.ត.ក ក៏ខុសពី តុលាការ "អន្តរជាតិតូបនីយកម្ម" ផ្សេងទៀត ដែលមានលក្ខណៈជាអន្តរជាតិ ដោយសារតែតុលាការទាំងនោះ បង្កើតឡើងដោយកិច្ចព្រមព្រៀងអន្តរជាតិ។ ជាលទ្ធផល តុលាការ"អន្តរជាតិតូបនីយកម្ម" ទាំងនោះ មិនមែនជាផ្នែកនៃតុលាការថ្នាក់ជាតិទេ[18]។

២៦. ផ្ទុយមកវិញ អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយសារតែកិច្ចព្រមព្រៀងត្រូវបានអនុម័តយល់ព្រមដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ អ.វ.ត.ក ត្រូវបានគេឯកភាពគ្នាថាជាតុលាការនៅក្នុងប្រព័ន្ធតុលាការកម្ពុជា [19] ហើយតុលាការនេះ ត្រូវបានទទួលស្គាល់ថាជាតុលាការជាតិ។ [20] អ.វ.ត.ក មានសមត្ថកិច្ចអនុវត្តយុត្តាធិការលើបទល្មើសជាតិនិងបទល្មើសអន្តរជាតិ។ [21] អ.វ.ត.ក "ត្រូវបានគ្របដណ្តប់ដោយធម្មនុញ្ញកម្ពុជា និងច្បាប់ជាតិ" [22]

---

ដែលអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា 'តុលាការមានយុត្តាធិការតែលើប ទឧក្រិដ្ឋដែលត្រូវបានចុះបញ្ជីនៅក្នុង [លក្ខន្តិកៈ] ប្រសិនបើបទឧក្រិដ្ឋនោះត្រូវបានទទួលស្គាល់ថាដូច្នោះ នៅក្រោមច្បាប់ ទំនៀមទម្លាប់អន្តរជាតិ នៅពេលដែលបទឧក្រិដ្ឋនោះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តិឡើង។ ហេតុនេះ គេអាចនិយាយបានថា វិសាលភាពនៃលក្ខណៈ (ratione material) យុត្តាធិការរបស់តុលាការនេះត្រូវសម្រេចដោយលក្ខន្តិកៈច្បាប់ក៏បាន (ដូចដែលថា វាបានចែងនៅក្នុងក្របខណ្ឌនៃយុត្តាធិការរបស់តុលាការអន្តរជាតិ) និងដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏បាន (ដូចដែលថា អំណាចរបស់តុលាការក្នុងការផ្តន្ទាទោសជនជាប់ចោទណាម្នាក់ពីបទឧក្រិដ្ឋណាមួយដែលមានចែងនៅក្នុងលក្ខន្តិកៈ វាអាស្រ័យទៅលើអត្ថិភាពនៃទំនៀមទម្លាប់ នៅពេលដែលបទឧក្រិដ្ឋនេះត្រូវបានប្រព្រឹត្តឡើង)។

[17] សូមមើល Guénaël Mettraux, *International Crimes and the Ad Hoc Tribunals* (2005), ទំព័រ៦-៧។

[18] Antonio Cassese, *International Criminal Law* (2000), ទំព័រ៣៤៣។

[19] សូមមើល Antonio Cassese, *International Criminal Law* (2000), ទំព័រ៣៤៣។

[20] អ.ប.ជ, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧, កថាខណ្ឌ១៩៖ "អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យ ហើយដំណើរប្រតិបត្តិការរបស់ខ្លួនក៏ឯករាជ្យផងដែរ នៅក្នុងរចនាសម្ព័ន្ធតុលការជាតិ [...]"។ សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ១៣០០។

[21] កិច្ចព្រមព្រៀង មាត្រា១។

ហេតុដូចនេះ តុលាការនេះ ត្រូវជាប់កាតព្វកិច្ចគោរពច្បាប់កម្ពុជា។ រាល់ការលើកឡើងដែលថា អ.វ.ត.ក មិនមែនជា តុលាការ"អន្តរជាតិ" ប៉ុន្តែជាទម្រង់តុលាការកូនកាត់ ក៏ការលើកឡើងនេះ បង្ហាញថា អ.វ.ត.ក ជាផ្នែកនៃប្រព័ន្ធតុលាការជាតិដែរ។

២៧. ជាផលវិបាក និងផ្ទុយពីការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត[23] ច្បាប់អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ផ្តល់នូវមូលដ្ឋានមិនគ្រប់គ្រាន់ដើម្បីកាត់សេចក្តីដើមបណ្តឹងឧទ្ធរណ៍ចំពោះតុលាការនេះ។ អ.វ.ត.ក អាចកាត់សេចក្តីតែបទល្មើសអន្តរជាតិ ប្រសិនបើបទល្មើសនោះ ត្រូវបានកំណត់ត្រឹមត្រូវថាជាបទល្មើសព្រហ្មទណ្ឌ ផ្អែកតាមច្បាប់ជាតិនៃប្រទេសកម្ពុជា មុនពេល ឬនៅពេលប្រព្រឹត្តិបទល្មើសនោះ។

*ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌ ផ្អែកតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បន្ទាប់ពីការសម្រេចចូលជាសមាជិករបស់ប្រទេសកម្ពុជាទៅក្នុងអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*

២៨. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ សន្និដ្ឋានថា "បទប្បញ្ញត្តិនៃច្បាប់អន្តរជាតិ ដែលចែងអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ [...]ដែលបានកំណត់យ៉ាងច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺមានអនុភាព

---

[22] សៀវភៅនិពន្ធដោយ Suzannah Linton, មានចំណងជើងថា 'Putting Cambodia's Extraordinary Chambers into Context' (2007) 11 បោះពុម្ពដោយ *Singapore Year Book of International Law and Contributors* ទំព័រ195, 225។

[23] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ១៣០២ "ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិក្នុងពេលដែលអំពើនោះកើតឡើងនោះទេ នោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ ឬដោយតុល្យភាពហើយអំពើនោះក៏ត្រូវតែជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិដែរអនុវត្តនៅក្នុងប្រទេសកម្ពុជានៅខណៈពេលដែលអំពើនោះបានកើតឡើងផងដែរ'។

គតិយុត្តចាប់បង្ខំតម្រូវឱ្យកម្ពុជាត្រូវតែគោរពតាម [...]"[24] ។ សហចៅក្រមស៊ើបអង្កេតលើកឡើងបន្ថែមទៀតថា ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានចូលជាធរមាននៅឆ្នាំ១៩៥១ ហេតុដូច្នេះ "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានចាត់ជាបទល្មើសនៅក្នុងច្បាប់ អន្តរជាតិដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង"[25] ។ មាត្រា៥នៃ អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តម្រូវឱ្យរដ្ឋភាគីកំណត់បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាបទព្រហ្មទណ្ឌ[26] ហើយប្រសិនបើគ្មានការកំណត់បែបនោះទេឧក្រិដ្ឋកម្មប្រល័យ ពូជសាសន៍ មិនអាចយកមកប្រើដើម្បីកាត់សេចក្តីនៅក្នុងប្រព័ន្ធជាតិបានទេ។ ការតាក់តែងច្បាប់ ត្រូវបានតម្រូវផងដែរ ដើម្បីកំណត់បទល្មើសអន្តរជាតិជាបទព្រហ្មទណ្ឌនៅក្នុងប្រព័ន្ធច្បាប់ជាតិ និងចែងអំពីទោសបញ្ញត្តិសមស្រប។ ប្រការដែលថា ប្រទេសកម្ពុជា និងរដ្ឋភាគីជាច្រើនផ្សេងទៀត បានខកខានមិនបានតាក់តែងច្បាប់នៅដំណាក់កាលដំបូងមក មានន័យថាប្រទេសកម្ពុជាអាចរំលោភបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ករណីនេះ មិនមែនបង្កប់ន័យថា យុត្តាធិការជាសាកលចំពោះបទល្មើសនេះត្រូវបានបង្កើតឡើងដោយគ្មានលក្ខខណ្ឌតម្រូវត្រឹមត្រូវសម្រាប់បង្កើតនូវមូលដ្ឋានច្បាប់បែបនោះទេ។

២៩. មេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេត មិនអាចផ្អែកលើការចូលជាសមាជិករបស់ប្រទេសកម្ពុជាទៅក្នុងអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដើម្បីធ្វើជាយុត្តិកម្មថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គឺជាផ្នែកនៃច្បាប់អន្តរជាតិ ដែលអាចយកមកអនុវត្តបាននៅក្នុងប្រទេសកម្ពុជានៅពេលប្រព្រឹត្តនោះទេ។ ដោយសារតែ អ.វ.ត.ក គឺជាផ្នែកនៃប្រព័ន្ធតុលាការកម្ពុជា ច្បាប់ព្រហ្មទណ្ឌ

---

[24] ដីកាដំណោះស្រាយ កថាខណ្ឌ១៣០៥។

[25] ដីកាដំណោះស្រាយ កថាខណ្ឌ១៣១០។

[26] មាត្រា៥ នៃអនុសញ្ញាប្រល័យពូជសាសន៍ចែងថា៖ "[]ភាគីទាំងឡាយ មានភារកិច្ចអនុម័តតាមក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញរៀងៗខ្លួននូវច្បាប់ជាចាំបាច់ដើម្បីធ្វើឱ្យបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះមានប្រសិទ្ធិភាព និងជាពិសេសដើម្បីធ្វើឱ្យមានប្រសិទ្ធភាព ដល់ទណ្ឌកម្មនានាដែលត្រូវធ្វើចំពោះមនុស្ស ដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឬ អំពើណាមួយទៀតដែលរៀបរាប់ក្នុងមាត្រា៣ ខាងលើ។' សូមមើល សៀវភៅនិពន្ធដោយ William A. Schabas, មានចំណងជើងថា *Genocide in International Law* (2000), ត់ព័រ346 រៀបរាប់ពីមាត្រា៥ នៃអនុសញ្ញាប្រល័យពូជសាសន៍ថាជា "កាតព្វកិច្ចអនុវត្តច្បាប់ជាតិ" ចំពោះប្រទេសហត្ថលេខី។

អន្តរជាតិសារធាតុដែលផ្អែកលើអនុសញ្ញាអន្តរជាតិ មិនអាចយកមកអនុវត្តដោយផ្ទាល់នោះទេ។ បទល្មើសអន្តរជាតិ ដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិ អាចយកមកអនុវត្តផ្ទាល់ចំពោះតុលាការ ដែលជាប្រព័ន្ធតុលាការជាតិតែប៉ុណ្ណោះ ប្រសិនបើបទប្បញ្ញត្តិពាក់ព័ន្ធ ត្រូវបានតាក់តែងនៅក្នុងច្បាប់ជាតិ។ បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនមានចែងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥-១៩៧៩។

៣០. ទោះបីជាកម្ពុជាបានក្លាយជាសមាជិកនៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងឆ្នាំ ១៩៥០ ក៏ដោយ ក៏កម្ពុជាមិនទាន់បានអនុម័តច្បាប់លើបទល្មើសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះនៅឡើយទេ ហើយក៏មិនតម្រូវឲ្យមានការទទួលខុសត្រូវអ្វីឡើយចំពោះការដែលគ្មានច្បាប់នោះដែរ[27]។ ដូចដែលបានលើកទឡ្ហីករណ៍ពីមុន ច្បាប់ អ.វ.ត.ក មិនអាចចាត់ទុកថាបានបង្កើតនូវការអនុវត្តច្បាប់ចាំបាច់សម្រាប់ច្បាប់អនុសញ្ញាដើម្បីអាចអនុវត្តផ្ទាល់នៅ អ.វ.ត.ក ចំពោះអំពើនានា ដែលបានកើតឡើងនៅឆ្នាំ ១៩៧៥-៧៩ ដោយសារតែវាត្រូវបានតាក់តែងជាង៥០ឆ្នាំ ក្រោយពេលដែលប្រទេសកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង៣០ឆ្នាំក្រោយពេលការប្រព្រឹត្តិនៃអំពើពាក់ព័ន្ធទាំង នោះ។

៣១. ថាតើប្រទេសកម្ពុជាប្រើប្រាស់ប្រព័ន្ធទ្វិកនិយម ឬឯកនិយម គឺមិនពាក់ព័ន្ធនៅក្នុងការពិភាក្សានេះទេ។ ក្រោយពីចូលជាសមាជិករបស់អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ វាចាំបាច់ក្នុងការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានៅក្នុងប្រព័ន្ធជាតិ ដើម្បីបង្កើតយុត្តាធិការក្នុងការកាត់សេចក្តីបទឧក្រិដ្ឋទាំងនោះ និងចែងអំពីទោសប្បញ្ញត្តិ។

---

[27] សូមមើល សៀវភៅនិពន្ធដោយ William A. Schabas, មានចំណងជើងថា *Genocide in International Law* (2000), តំព័រ350

៣២. ផ្ទុយគ្នានឹងប្រព័ន្ធ "ទ្វិក" និយម[28] ផ្អែកតាមប្រព័ន្ធ "ឯកនិយម" "ការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក សន្ធិសញ្ញាអន្តរជាតិ ធ្វើឱ្យបទដ្ឋាននៃសន្ធិសញ្ញា ក្លាយជាច្បាប់ជាតិ និងធ្វើឱ្យច្បាប់ទាំងនោះអាចអនុវត្តដោយផ្ទាល់ចំពោះតុលាការជាតិ"[29] ។ ប៉ុន្តែ អនុសញ្ញាបែបនេះ ត្រូវតែមាន "អានុភាពអនុវត្តដោយខ្លួនឯង" ដើម្បីអាចយកប្រើប្រាស់ដោយផ្ទាល់ និងអនុវត្តនៅក្នុងច្បាប់ជាតិ[30]។ អនុសញ្ញាត្រូវបានចាត់ទុកថាមាន "អានុភាពអនុវត្តដោយខ្លួនឯង" ប្រសិនបើ "អនុសញ្ញានោះបានព្រាងឡើងក្នុងរបៀបដែលអាចយកមកអនុវត្តដោយមិនមានការបន្ថែម ឬការកែប្រែផ្សេងទៀត"[31] ។ ដូច្នេះ អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនអាចចាត់ទុកថាជាអនុសញ្ញាមាន "អានុភាពអនុវត្តដោយខ្លួនឯង" នោះទេ។ ទីមួយ បទប្បញ្ញត្តិនៃអនុសញ្ញានេះ មិនអាចយកមកអនុវត្តដោយមិនមានការតាក់តែងច្បាប់ជាតិនោះទេ។ មាត្រា៥នៃអនុសញ្ញា តម្រូវយ៉ាងច្បាស់ឱ្យរដ្ឋភាគីតាក់តែងច្បាប់ដើម្បីកំណត់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងអំពើដែលមានរៀបរាប់ផ្សេងទៀត នៅក្នុងអនុសញ្ញា ជាបទព្រហ្មទណ្ឌ។ ទីពីរ ទោសប្បញ្ញត្តិចំពោះបុគ្គលទាំងឡាយជាប់ពិរុទ្ធភាពនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនមានចែងនៅក្នុងអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ដោយសារតែប្រទេសកម្ពុជាមិនបានតាក់តែងច្បាប់សមស្រប ដូចនេះទោសប្បញ្ញត្តិនៃបទល្មើស បែបនេះ មិនមានចែងនៅក្នុងច្បាប់ជាតិនៃប្រទេសកម្ពុជា នៅក្នុងពេលវេលាដែលពាក់ព័ន្ធនោះទេ។ មេធាវីការពារក្តីរំឮកឡើងវិញថា "វាចាំបាច់ក្នុងការចែងក្នុងច្បាប់អំពីកម្រិតនៃការផ្តន្ទាទោសចំពោះបទល្មើសនីមួយៗ [...] ដើម្បីបញ្ជាក់ឱ្យដឹងអំពី ការផ្តន្ទាទោសដែលអាចមាន ដែលអាចកំណត់ ដាក់ទោស

---

[28] ប្រទេសដែលប្រកាន់យកប្រព័ន្ធទ្វិកនិយម បែងចែកច្បាប់អន្តរជាតិដាច់ដោយឡែកពីច្បាប់ជាតិ។ ដូច្នេះ ច្បាប់អន្តរជាតិអាចត្រូវបានអនុវត្តតែនៅក្នុងប្រព័ន្ធទាំងនោះប៉ុណ្ណោះ ប្រសិនបើការអនុវត្តផ្ទាល់ត្រូវបានអនុញ្ញាតិយ៉ាងជាក់លាក់ ដោយរដ្ឋធម្មនុញ្ញ ឬប្រសិនបើច្បាប់ជាតិជាធរមានបានបញ្ចូលច្បាប់អន្តរជាតិទៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ប្រទេស។ សូមមើល Ward N. Ferdinandusse, *Direct Application of International Criminal Law in National Courts* (2006), ទំព័រ129។

[29] សូមមើលសៀវភៅនិពន្ធដោយ William A. Schabas, មានចំណងជើងថា *Genocide in International Law* (2000), ទំព័រ 350។

[30] សូមមើលសៀវភៅនិពន្ធដោយ William A. Schabas, មានចំណងជើងថា *Genocide in International Law* (2000), ទំព័រ 350។

[31] សូមមើលសៀវភៅនិពន្ធដោយ William A. Schabas, មានចំណងជើងថា *Genocide in International Law* (2000), ទំព័រ 350។

ប្រសិនបើជនណាម្នាក់ បានបំពារបំពានលើបទប្បញ្ញត្តិព្រហ្មទណ្ឌណាមួយ"។ [32] មេធាវីការពារក្តី លើកឡើងថា ទោះបីជាគោលការណ៍បែបនេះ មិនអាចមានលក្ខណៈអាចយកមក អនុវត្តបាន នៅកម្រិតអន្តរជាតិ ចំពោះមុខតុលាការ *មិនអចិន្ត្រៃយ៍*នានាក្តី [33] ក៏វាអាចយកមកអនុវត្ត បាន នៅអ.វ.ត.ក ដែលជាផ្នែកនៃប្រព័ន្ធតុលាការកម្ពុជា។

៣៣. បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនត្រូវបានកំណត់ជាបទព្រហ្មទណ្ឌនៅក្នុងច្បាប់នៃប្រទេសកម្ពុជា នៅឆ្នាំ ១៩៧៥-៧៩ឡើយ។ បន្ថែមពីលើនេះ មិនមានចែងអំពីទោសប្បញ្ញត្តិចំពោះការប្រព្រឹត្តិបទល្មើស បែបនោះទេ។ ដោយសារមូលហេតុនេះ អ.វ.ត.ក មិនមានយុត្តាធិការលើបទល្មើសនេះ ហើយ ដើមបណ្តឹងឧទ្ធរណ៍មិនអាចត្រូវបានគេចោទប្រកាន់ និងជំនុំជម្រះក្តីដោយសារបទល្មើស នេះទេ។[34]

៣៤. ចំណុចចុងក្រោយ សហចៅក្រមស៊ើបអង្កេត មិនបានរកឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជា ផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលពាក់ព័ន្ធនោះទេ។ នៅក្នុងកាលៈទេសៈនេះ មេធាវី ការពារក្តី នឹងមិន លើកឡើងទាក់ទិននឹងចំណុចនេះទេ។ ប្រសិនបើ ទឡ្ហីករណ៍របស់មេធាវី ការពារក្តី អាច ជួយដល់ អ.ប.ជ ទឡ្ហីករណ៍នេះអាចនឹងត្រូវលើកឡើងនៅក្នុងអំឡុងពេលសវនាការ ផ្ទាល់មាត់។

៣.៣.៤ <u>ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានព្យាករណ៍ទុកជាមុន និងមិនអាចដឹងបានពីបទឧក្រិដ្ឋប្រល័យពូជ សាសន៍នោះឡើយ</u>

៣៥. បើតាមគោលការណ៍ *គ្មានទោសបើគ្មានច្បាប់ចែង* គេត្រូវសម្រេចថាតើទង្វើនៅពេលប្រព្រឹត្តនូវបទ ឧក្រិដ្ឋនោះអាចផ្តន្ទាទោសបាន ឬយ៉ាងណា ដើម្បីសម្រេចថាតើគួរវិនិច្ឆ័យទោសដល់បុគ្គលណាម្នាក់

---

[32] Antonio Cassese, *International Criminal Law* (2003), ទំព័រ 157។

[33] Antonio Cassese, *International Criminal Law* (2003), ទំព័រ 157។

[34] សូមមើល ឧទាហរណ៍, រឿងក្តី *Nulyarimma* *តទល់នឹង* Thompson [1999] FCA 1192 ដែលតុលាការសហព័ន្ធអូស្ត្រាលី (Federal Court of Australia) បានលើកឡើងថា៖ 'និយាយដូច្នេះវាមិនគ្រប់គ្រាន់ទេ នៅក្រោមច្បាប់អន្តរជាតិ បទឧក្រិដ្ឋអន្តរជាតិ អាចត្រូវបានផ្តន្ទាទោស នៅក្នុងតុលាការថ្នាក់ជាតិ ទោះបីជាមិនមានច្បាប់ជាតិចែងថាទង្វើនោះត្រូវផ្តន្ទាទោសក៏ដោយ។ ប្រសិន បើអំពើប្រល័យពូជសាសន៍ត្រូវបានកំណត់ថាអាចត្រូវផ្តន្ទាទោសនៅក្នុងប្រទេសអូស្ត្រាលី ដោយសំអាងលើមូលដ្ឋានថាវាជាឧក្រិដ្ឋកម្ម អន្តរជាតិនោះ វាត្រូវបង្ហាញឲ្យឃើញថាប្រទេសអូស្ត្រាលីអនុញ្ញាតិឲ្យលទ្ធផលនោះ'។

ចំពោះការប្រព្រឹត្តនោះឬយ៉ាងណាឡើយ[35]។ និយាយម្យ៉ាងវិញទៀត "ចារីដែលទទួលការចោទប្រកាន់ត្រូវតែបានដឹងជាមុន និងទទួលបានថា ទង្វើជាក់លាក់របស់ខ្លួន អាចត្រូវផ្ដន្ទាទោសបាន"[36]។

៣៦. ដីកាដំណោះស្រាយបានរៀបរាប់ថា ដោយសារបទប្បញ្ញត្តិនៃច្បាប់អន្តរជាតិដែលទប់ស្កាត់បទឧក្រិដ្ឋប្រល័យពូជសាសន៍បានចងកាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះប្រទេសកម្ពុជា គេអាចចាត់ទុកថាជនត្រូវចោទអាចទទួលបានព័តមានយ៉ាងពេញលេញហើយ[37]។ សហមេធាវីការពារក្ដីសូមស្នើថា សេចក្ដីសន្និដ្ឋាននេះមិនត្រឹមត្រូវទេ។ សហចៅក្រមស៊ើបអង្កេតខកខានមិនបានធ្វើការបែងចែកឱ្យដាច់ស្រឡះជាមូលដ្ឋាន រវាងបទប្បញ្ញត្តិអន្តរជាតិ "ដែលទប់ស្កាត់" បទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលចងកាតព្វកិច្ច ចំពោះរដ្ឋជាភាគី និងបទប្បញ្ញត្តិច្បាប់អន្តរជាតិ "ដែលចែងជាបទល្មើសព្រហ្មទណ្ឌ" ចំពោះបទឧក្រិដ្ឋបែបនេះ ដែលចងកាតព្វកិច្ចចំពោះប្រជាពលរដ្ឋរបស់រដ្ឋជាភាគី។ សហមេធាវីការពារក្ដីស្នើថា សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានដោយខុសឆ្គងថា ការហាមឃាត់នោះបានធ្វើឱ្យបុគ្គលម្នាក់ត្រូវទទួលខុសត្រូវបទឧក្រិដ្ឋ ចំពោះអំពើប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តនៅប្រទេសកម្ពុជាចន្លោះឆ្នាំ ១៩៧៥-៧៩។

៣៧. សហមេធាវីការពារក្ដីស្នើថា បទប្បញ្ញត្តិដែលទប់ស្កាត់បទឧក្រិដ្ឋប្រល័យពូជសាសន៍មិនចងកាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះប្រជាជនកម្ពុជា ដូចជាច្បាប់ព្រហ្មទណ្ឌសារធាតុ នៅថ្នាក់ជាតិ ដែលបានចែងជាបទល្មើសព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តឡើយ។ ជាងនេះទៅទៀត នៅពេលនោះមិនទាន់មានការផ្ដន្ទាទោសចំពោះការប្រព្រឹត្តអំពើនោះទេ។ អាស្រ័យហេតុនេះ នៅចន្លោះឆ្នាំ១៩៧៥-៧៩ ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនទាន់បានដឹងមុនអំពីច្បាប់ដែលចែងជាបទល្មើសព្រហ្ម

[35] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Hadzihasanovic និងអ្នកផ្សេងទៀត*, សេចក្ដីសម្រេចស្ដីពីការជំទាស់ទៅលើយុត្តាធិការ, រឿងក្ដីលេខ IT-01-47-PT ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ៦២។

[36] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Hadzihasanovic និងអ្នកផ្សេងទៀត*, សេចក្ដីសម្រេចស្ដីពីការជំទាស់ទៅលើយុត្តាធិការ, រឿងក្ដីលេខ IT-01-47-PT ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ៦២។

[37] ដីកាដំណោះស្រាយ កថាខណ្ឌ១៣០៥។

ទណ្ឌ ចំពោះអំពើនោះឡើយ ហើយម្ចាស់បណ្ដឹងឧទ្ធរណ៍ក៏មិនអាចបានដឹងជាមុនថា អំពើដែលប្រព្រឹត្ត ចន្លោះឆ្នាំ១៩៧៥-៧៩ ជាបទឧក្រិដ្ឋដែរ។

## ៣.៤ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣៨. ច្បាប់ស្ដីពីការបង្កើតអវតក ចែងថា "អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ក្នុងអំឡុងពេលដែលស្ថិតក្រោមកិច្ចស៊ើបសួរ។ ច្បាប់ស្ដីពីការបង្កើត អវតក ក៏បានចែងបន្ថែមទៀតថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ណាមួយ ដូចជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា អំពើអមនុស្សធម៌ផ្សេងទៀត"[38]។

៣៩. មាត្រា៦(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT)[39] បានកំណត់និយមន័យរបស់ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដូចតទៅ៖ "ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិល នៅមុនពេល ឬអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនាក្នុងការប្រព្រឹត្ត ឬក្នុងទំនាក់ទំនងជាមួយបទឧក្រិដ្ឋណាមួយដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការនេះ ទោះបីនៅពេលប្រព្រឹត្តនោះមានការរំលោភ ឬមិនមានការរំលោភទៅលើច្បាប់ក្នុងស្រុករបស់ប្រទេសនោះក៏ដោយ"។

---

[38] ច្បាប់ស្ដីពីការបង្កើត អវតក មាត្រា៥។

[39] ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ អនុម័តនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥។

៤០. សហមេធាវីការពារក្តីស្នើថា អ.វ.ត.ក មិនមានយុត្តាធិការក្នុងការវិនិច្ឆ័យទោសម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។

៣.៤.១ <u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនបង្កើតបានជាបទល្មើសព្រហ្មទណ្ឌនៅក្នុងច្បាប់ជាតិរបស់កម្ពុជាទេ</u>

៤១. មាត្រា៣៣(២)(ថ្មី)នៃច្បាប់ អ.វ.ត.ក ទទួលស្គាល់ថា នៅក្នុងច្បាប់ជាតិ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនមានពិរុទ្ធភាពលើបទល្មើសព្រហ្មទណ្ឌទេ ចំពោះបទចោទប្រកាន់លើអំពើណាមួយ ឬបទល្មើសណាមួយ ដែលបង្កើតជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែលបានប្រព្រឹត្តនូវអំពើនោះ។

៤២. សហមេធាវីការពារក្តីស្នើថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនមែនជាបទឧក្រិដ្ឋនៅប្រទេសកម្ពុជានៅចន្លោះឆ្នាំ១៩៧៥-៧៩ទេ។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលត្រូវបានគេទទួលស្គាល់យ៉ាងច្បាស់ថា ជាក្រមព្រហ្មទណ្ឌដែលនៅជាធរមានក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ [40] មិនបានចែងជាបទល្មើសព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅកម្ពុជាទេ។

៤៣. ការវិនិច្ឆ័យទោសម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងរំលោភដល់គោលការណ៍ *គ្មានទោសបើគ្មានច្បាប់ចែង* ដែលគោលការណ៍នេះតម្រូវថា អំពើណាមួយអាចយកមកផ្តន្ទាទោសបាន លុះត្រាតែអំពើនោះត្រូវបានចែងជាបទល្មើសព្រហ្មទណ្ឌនៅពេលប្រព្រឹត្ត។[41]

៣.៤.២ <u>ច្បាប់ អ.វ.ត.ក មិនអាចបង្កើតច្បាប់ថ្មី និងអនុវត្តច្បាប់ជាប្រតិសកម្មបានទេ</u>

៤៤. សហមេធាវីការពារក្តីសូមយោងទៅដល់មូលដ្ឋាននានាដែលមាននៅក្នុងសំណើរបស់ខ្លួននៅផ្នែក ៣.៣.២ ខាងលើ ដោយយកមកអនុវត្តដូចគ្នាចំពោះសំណើនេះទាក់ទិននឹងការមិនមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅចំពោះមុខតុលាការនេះ។

---

[40] អ.ប.ជ, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេចអ៊ាវ ហៅ "ឌុច" ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ១៩។ សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ១៣០០។

[41] Antonio Cassese, *International Criminal Law* (ឆ្នាំ២០០៣) ទំព័រ១៤២។

៤៥. ដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនត្រូវបានចែងជាបទល្មើសព្រហ្មទណ្ឌ ក្រោមច្បាប់កម្ពុជាក្នុងពេលដែលអង្គហេតុបានកើតឡើង សហមេធាវីការពារក្តីស្នើថាសហចៅក្រមស៊ើបអង្កេតបានបកស្រាយច្បាប់ អ.វ.ត.ក ដោយខុសឆ្គង តាមវិធីនេះ ដើម្បីអាចបង្កើតជាច្បាប់ព្រហ្មទណ្ឌថ្មីមួយ និងអនុវត្តច្បាប់បែបនេះជាប្រតិសកម្ម ហេតុនេះវាជាការរំលោភលើគោលការណ៍មូលដ្ឋានពីរគឺ៖ គោលការណ៍ *គ្មានទោសបើគ្មានច្បាប់ចែង* និងគោលការណ៍នៃភាពមិនមានប្រតិសកម្មចំពោះច្បាប់ព្រហ្មទណ្ឌថ្មី។

៣.៤.៣ <u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជា "បទឧក្រិដ្ឋអន្តរជាតិ" មិនអាចយកមកអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក បានទេ</u>

៤៦. សហមេធាវីការពារក្តីស្នើថា ការទប់ស្កាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចយកជាមូលដ្ឋាន សម្រាប់ធ្វើការវិនិច្ឆ័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក បានទេ។

*អ.វ.ត.ក មិនមែនជាតុលាការ "អន្តរជាតិ" ដែលត្រូវអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់ទេ។*

៤៧. ខុសពីតុលាការពិសេស អ.វ.ត.ក ជាផ្នែកមួយរបស់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ហើយហេតុនេះ ច្បាប់អន្តរជាតិរួមទាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិផង មិនអាចត្រូវបានយកមកអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក បានទេ។

៤៨. សហមេធាវីការពារក្តីសូមយោងទៅលើការវិភាគរបស់ខ្លួនពីភាពខុសគ្នារវាងតុលាការអន្តរជាតិ និង អ.វ.ត.ក ដូចដែលមានរៀបរាប់នៅផ្នែក ៣.៣.៣ ខាងលើ។

*"ការចែងជាបទល្មើសព្រហ្មទណ្ឌ" ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងពេលដែលអង្គហេតុបានកើតឡើងឡើយ។*

៤៩. បើតាមសហចៅក្រមស៊ើបអង្កេត ការទប់ស្កាត់មួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមាននៅក្នុងច្បាប់ទំនៀមទម្លាប់ ក្នុងពេលដែលអង្គហេតុបានកើតឡើង ហើយថា ការទប់ស្កាត់បែបនេះ "ត្រូវបានម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលព័ត៌មានបានយ៉ាងពេញលេញ"[42]។

៥០. សហមេធាវីការពារក្តីស្នើថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានទទួលស្គាល់ពីភាពខុសគ្នាជាមូលដ្ឋានរវាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ "ដែលទប់ស្កាត់" ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលចងកាតព្វកិច្ចដល់រដ្ឋ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ "ដែលចែងជាបទល្មើសព្រហ្មទណ្ឌ" ចំពោះអំពើទាំងនោះដែលបានប្រព្រឹត្តដោយបុគ្គល។ ភាពខុសគ្នាជាមូលដ្ឋាននេះដោយសារថា "សូម្បីតែពេលដែលតុលាការនេះទទួលស្គាល់ថា ការហាមឃាត់ជាក់លាក់ណាមួយមាននៅក្នុងទម្លាប់អន្តរជាតិក៏ដោយ ក៏គេត្រូវសម្រេចថា ការហាមឃាត់នេះអាចអនុវត្តចំពោះបុគ្គលបាន (មិនត្រឹមតែអនុវត្តចំពោះរដ្ឋទេ) [...] ហើយថា ការរំលោភបំពានចំពោះការហាមឃាត់នោះ នឹងតម្រូវឱ្យមានការទទួលខុសត្រូវបទឧក្រិដ្ឋនោះជាលក្ខណៈបុគ្គល ទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។[43] ដីកាដំណោះស្រាយខកខានមិនបានធ្វើបែបនេះទេ។ ការដែលគ្រាន់តែយោងទៅដល់សវនាការនានាក្នុងសម័យសង្គ្រាមលោកលើកទី២ មិនបានបង្កើតជាបទដ្ឋានទំនៀមទម្លាប់ ដែលចែងជាបទល្មើសព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានកើតឡើងចន្លោះឆ្នាំ១៩៧៥-៧៩នោះឡើយ។ ប្រការនេះកើតឡើងដោយសារ មិនមានវិធានពាក់ព័ន្ធនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលតម្រូវឱ្យរដ្ឋមួយត្រូវផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះឆ្នាំ១៩៧៥-៧៩ នៅកម្ពុជាឡើយ។[44]

---

[42] ដីកាដំណោះស្រាយ កថាខណ្ឌ១៣០៦។

[43] Guénaël Mettraux, *International Crimes and the Ad Hoc Tribunals* (ឆ្នាំ២00៥) ទំព័រ១៣។

[44] គណៈកម្មការច្បាប់អន្តរជាតិបានទប់ស្កាត់នៅទសវត្សរ៍ឆ្នាំ១៩៥0 ហើយក្រោយមកមានការលំបាកចន្លោះឆ្នាំ១៩៨២-១៩៨៦ ក្នុងការស្វែងរកទស្សនៈគោលនយោបាយមួយស្តីពីការចែងជាបទល្មើសព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការលាតសន្ធឹងទៅដល់ការរំលោភសិទ្ធិមនុស្សអាច ឬគួរតែបង្កើតជាបទល្មើសព្រហ្មទណ្ឌជាអន្តរជាតិ។ សូមមើល Cherif Bassiouni, *Crimes Against Humanity in International Criminal Law* (ឆ្នាំ១៩៩៩) ទំព័រ១៨៥។

៥១. អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតខកខានមិនបានបង្ហាញថា វិសាលភាពនៃវិធានរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងពេលដែលអង្គហេតុបានកើតឡើងនោះបានលាតសន្ធឹងទៅដល់ការចែងជាបទល្មើសព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តរបស់បុគ្គល នៅក្នុងប្រទេសកម្ពុជាឡើយ។[45] ក្នុងការសម្រេចថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចាត់ជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង" [46] សហចៅក្រមស៊ើបអង្កេតបានយោងទៅដល់ធម្មនុញ្ញនៅ Nuremberg ឆ្នាំ១៩៤៥ និងអនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(CNASL)[47]។ សហមេធាវីការពារក្តីស្នើថា សហចៅក្រមស៊ើបអង្កេតភាន់ច្រឡំក្នុងការបង្ហាញពីភាពដែលអាចជឿជាក់បាននៃឯកសារទាំងនេះ។

៥២. ធម្មនុញ្ញនៅ Nuremberg មិនបានបង្កើតជាវិធានមួយចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ហើយវាក៏មិនបានរៀបចំវិធាននោះទៅជាក្រមនោះដែរ ដោយណែនាំឱ្យរដ្ឋជាអ្នកចែងជាបទល្មើសព្រហ្មទណ្ឌ និងវិនិច្ឆ័យទោសបុគ្គលទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជាងនេះទៀត ធម្មនុញ្ញនេះជាលិខិតបទដ្ឋានដែលត្រឹមតែផ្តល់នូវការណែនាំក្នុងការសម្រេចថាអ្វីជាឧក្រិដ្ឋសង្គ្រាមក្នុងសម័យសង្គ្រាមលោកលើកទី២ តែប៉ុណ្ណោះ។ ជាងនេះទៅទៀត ធម្មនុញ្ញនេះអនុវត្តតែចំពោះបទឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃសង្គ្រាមលោកលើកទី២ តែប៉ុណ្ណោះ។ ជាលទ្ធផល អត្ថបទនេះមិនត្រូវបានយកមកអនុវត្តចំពោះឧក្រិដ្ឋកម្មនានាដែលរងការចោទប្រកាន់ថាបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចន្លោះ

---

[45] សូមមើល Guénaël Mettraux, *International Crimes and the Ad Hoc Tribunals* (ឆ្នាំ២00៥) ទំព័រ១៤ ជាអ្នកដែលអះអាងនៅក្នុងបរិបទនៃតុលាការពិសេសដែលថា "ចៅក្រម [...] ជាអ្នកវាយតម្លៃក្នុងការពង្រីកវិសាលភាពរបស់វិធានមួយ ដែលគេនិយាយថាមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងទិដ្ឋភាពនៃការអនុវត្តរបស់រដ្ឋដែលមាន និង ទស្សនៈច្បាប់ដែលមាន"។

[46] ដីកាដំណោះស្រាយ កថាខណ្ឌ១៣១៣។

[47] ដីកាដំណោះស្រាយ កថាខណ្ឌ១៣១៣ ជើងទំព័រ ៥១៨២ អនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុម័តដោយសេចក្តីមហាសន្និបាតអង្គការសហប្រជាជាតិលេខ 2391 (XXIII) នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ចូលជាធរមាននៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧0, បុព្វកថា និងមាត្រា១។

ឆ្នាំ១៩៧៥-៧៩ ឡើយ។ ជាងនេះទៀត នៅក្នុងធម្មនុញ្ញ Nuremberg ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចាត់ទុកថាជាឧក្រិដ្ឋសង្គ្រាម ហើយមិនមែនជាបទឧក្រិដ្ឋនោះទេ។[48]

៥៣. មកដល់ឆ្នាំ១៩៧៥ មានរដ្ឋត្រឹមតែ ១៧ ប៉ុណ្ណោះដែលចូលជាសមាជិក ឬបានផ្តល់សច្ចាប័នចំពោះ CNASL ហើយប្រទេសកម្ពុជាមិនទាន់ស្ថិតក្នុងចំណោមនោះទេ ហើយបច្ចុប្បន្នទៀតសោតក៏មិនមែនជាភាគីមួយរបស់អនុសញ្ញានេះដែរ[49]។ ហេតុនេះ CNASL មិនអាចយកមកអនុវត្តនៅប្រទេសកម្ពុជាបានឡើយ ក្នុងពេលដែលអង្គហេតុបានកើតឡើង ហើយវាក៏មិនបានបង្កើតជាបទដ្ឋានទំនៀមទម្លាប់មួយនៅក្នុងច្បាប់អន្តរជាតិ ដែលនឹងចែងជាបទល្មើសព្រហ្មទណ្ឌទេ ហើយវាមិនបានអនុញ្ញាតឱ្យធ្វើការវិនិច្ឆ័យទោសដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលនោះដែរ។

*ទឡ្ហីករណ៍ជាជម្រើស៖ បទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចយកមកអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក បានឡើយ*

៥៤. រដ្ឋមួយមិនអាចវិនិច្ឆ័យទោសដល់បុគ្គលណាម្នាក់ ដែលត្រូវបានចោទប្រកាន់ពីបទថាបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ លុះត្រាតែរដ្ឋនោះបានអនុម័តជាច្បាប់ដោយចែងជាបញ្ញត្តិថា ការរំលោភទាំងនោះជាបទល្មើសនៅក្រោមច្បាប់ក្នុងស្រុកជាមុនសិន[50] ដែលច្បាប់ក្នុងស្រុក

[48] Cherif Bassiouni *Crimes Against Humanity in International Criminal Law* (ឆ្នាំ១៩៩៩) ទំព័រ៤១, ៧៧។

[49] ១៧ រដ្ឋបានចូលជាសមាជិក ឬផ្តល់សច្ចាប័នដល់អនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មុនឆ្នាំ១៩៧៥ រួមមានប្រទេស អាល់បានី បេឡារុស ប៊ុលហ្គារី កាមេរូន គុយបា ហ្គីណេ ហុងគ្រី ឥណ្ឌា កេនយ៉ា ហ្វីលីពីន ប៉ូឡូញ រូម៉ានី សហព័ន្ធរុស្ស៊ី ទុយនីស៊ី និងអ៊ុយក្រែន។ ប្រទេសរ្វ៉ាន់ដា បានផ្តល់សច្ចាប័នដល់អនុសញ្ញានេះនៅឆ្នាំ១៩៧៥ និងប្រទេសហ្គាំប៊ី នៅឆ្នាំ១៩៧៨។

[50] Antonio Cassese, *International Criminal Law* (ឆ្នាំ២00៣) ទំព័រ៣0៣ ដែលបានអះអាងថា "តុលាការជាតិមិនចាត់វិធានការតាមកិច្ចដំណើរការនីតិវិធីចំពោះបទឧក្រិដ្ឋអន្តរជាតិ ដែលផ្អែកតែទៅលើមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺថា ប្រសិនបើបទឧក្រិដ្ឋមួយដែលត្រឹមតែមានចែងក្នុងផ្នែកមួយនៃច្បាប់នោះទេ"។

នោះក៏ត្រូវចែងពីការផ្តន្ទាទោសចំពោះការរំលោភបំពានទាំងនោះផងដែរ[51]។ គោលការណ៍នេះផ្អែកលើគោលការណ៍ពីរដែលមានទំនាក់ទំនងនឹងគ្នាគឺ គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* និងគោលការណ៍ភាពប្រាកដនិយមនៃច្បាប់។ ដោយសារ អ.វ.ត.ក ជាផ្នែកមួយរបស់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក អ.វ.ត.ក ត្រូវអនុវត្តតាមគោលការណ៍ទាំងពីរនេះ។

៥៥. នៅក្នុងទិដ្ឋភាពនេះ តុលាការប្រទេសបារាំងដែលជាមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌប្រទេសកម្ពុជា បានច្រានចោលមិនអនុវត្តដោយផ្ទាល់នៅតុលាការប្រទេសបារាំងចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារបទប្បញ្ញត្តិច្បាប់ក្នុងស្រុកមិនបានចែងជាបទល្មើសព្រហ្មទណ្ឌ ចំពោះទង្វើដែលពាក់ព័ន្ធនៅពេលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត (ចន្លោះឆ្នាំ១៩៧៥-៧៩)[52] ។ ដោយសារក្រមព្រហ្មទណ្ឌបារាំងទើបតែចែងបញ្ចូល ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងច្បាប់ក្នុងស្រុកនៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៩៤ នោះ រាល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមុនកាលបរិច្ឆេទនេះមិនត្រូវបានយកមកវិនិច្ឆ័យទោសថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។[53]

---

[51] Antonio Cassese, *International Criminal Law* (ឆ្នាំ២០០០) ទំព័រ៣០៣ ដែលអះអាងថា ផ្ទុយទៅវិញ រដ្ឋ "មានបំណងដាក់លក្ខខណ្ឌតម្រូវឱ្យមានលក្ខន្តិកៈជាតិមួយដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្ម និងផ្តល់នូវយុត្តាធិការដល់តុលាការថ្នាក់ជាតិទៅលើឧក្រិដ្ឋកម្មនេះ ឬប្រសិនរដ្ឋមួយផ្តល់សច្ចាប័នលើបញ្ហានេះនៅក្នុងសន្ធិសញ្ញាមួយ គឺតម្រូវឱ្យរដ្ឋនោះត្រូវអនុម័តជាច្បាប់សម្រាប់អនុវត្តដែលផ្តល់អំណាចពេញលេញដល់តុលាការរបស់ខ្លួន ទាក់ទិននឹងបទប្បញ្ញត្តិក្នុងសន្ធិសញ្ញាដែលពាក់ព័ន្ធ"។

[52] សាលាវិនិច្ឆ័យរបស់ប្រទេសបារាំង (French Cour de Cassation) ផ្នែកព្រហ្មទណ្ឌ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៣ ព្រឹត្តិបត្រផ្នែកព្រហ្មទណ្ឌឆ្នាំ២០០៣ លេខ១២២ ទំព័រ ៤៦៥។

[53] សូមមើល តុលាការកំពូលរបស់ប្រទេសហូឡង់ *រឿងក្តី Hoge Raad der Nederlanden* ក្រុងឡាអេ សាលដីកាចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០១ សំណុំរឿងលេខ AB1471 កថាខណ្ឌ៤.១-៤.៦ ដែលតុលាការកំពូលហូឡង់ បានសម្រេចថា ការវិនិច្ឆ័យទោសទៅលើឧក្រិដ្ឋកម្មក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិតែមួយ នឹងរំលោភដល់គោលការណ៍នីត្យានុកូលភាព ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញប្រទេសហូឡង់។ សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bagaragaza* សេចក្តីសម្រេចទៅលើបណ្តឹងរបស់រដ្ឋអាជ្ញាក្នុងការយោងទៅលើព្រះរាជាណាចក្រន័រវេយ៍ – វិធាន១១ស្ទួន នៃវិធានស្តីពីវិធីនិងភស្តុតាង សំណុំរឿងលេខ ICTR-2005-86-R11bis ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌ១៣៖ សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stankovic* សេចក្តីទៅលើការយោងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ

៥៦. រដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ជាធរមានដទៃទៀតមុននិងក្នុងអំឡុងពេលដែលពាក់ព័ន្ធ មិនបានចែងពីនីតិវិធីនៃការយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តក្នុងច្បាប់ជាតិទេ។ដូច្នេះគោលការណ៍ស្តីពីនីត្យានុកូលភាពបានហាមឃាត់ការយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តដោយផ្ទាល់ក្នុងប្រព័ន្ធច្បាប់កម្ពុជា។

៥៧. មាត្រា ១ និងមាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានបញ្ចូលពាក្យថា "ទម្លាប់" នៅក្នុងបទប្បញ្ញត្តិរបស់ខ្លួន ប៉ុន្តែច្បាប់នេះទើបតែត្រូវបានអនុម័តក្នុងឆ្នាំ២00១។ ការអនុញ្ញាតឱ្យច្បាប់បង្កើត អ.វ.ត.ក បញ្ចូលច្បាប់ទំនៀមទម្លាប់ទម្លាប់អន្តរជាតិដែលមានអានុភាពប្រតិសកម្ម ហើយដែលអាចកើតឡើងក្នុងអំឡុង ឆ្នាំ១៩៧៥-១៩៧៩ បែបនេះ នឹងបំពានលើគោលការណ៍: *គ្មានបទល្មើសបើគ្មានច្បាប់ចែង*។

*ដើមបណ្តឹងឧទ្ធរណ៍មិនអាចព្យាករណ៍និងទទួលបានព័ត៌មានពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេក្នុងអំពេលដែលពាក់ព័ន្ធ។*

*(១) និយមន័យនៃ "បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" មិនទាន់មានភាពប្រាកដប្រជានៅឡើយទេក្នុងទម្លាប់អន្តរជាតិ។*

៥៨. ប្រព័ន្ធច្បាប់ស៊ីវិល(Civil Law) បានចាត់ទុកទ្រឹស្តីនីត្យានុកូលភាពតឹងរ៉ឹងថាជាគោលការណ៍គ្រឹះ[54]។ សញ្ញាណជាមូលដ្ឋានមួយនៃទ្រឹស្តីនីត្យានុកូលភាពតឹងរ៉ឹងបានកំណត់ថា "ការអនុម័តច្បាប់ព្រហ្មទណ្ឌត្រូវតែគោរពតាមគោលការណ៍នៃភាពជាក់លាក់" [55]។ គោលការណ៍នៃភាពជាក់លាក់បានកំណត់ថា "វិធានច្បាប់ព្រហ្មទណ្ឌត្រូវតែមានភាពជាក់លាក់ និងពិស្តារគ្រប់គ្រាន់តាមដែលអាចធ្វើទៅបាន ដើម្បីចង្អុលបង្ហាញឱ្យបានច្បាស់នូវអំពើដែលច្បាប់បានហាមឃាត់ពោលគឺត្រូវច្បាស់ទាំងធាតុផ្សំសត្យានុមតិ

---

របស់រឿងក្តីក្រោមវិធាន១១ ស្ទួន សំណុំរឿងលេខ IT-96-23/2-PT ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២00៥ កថាខណ្ឌ៣២ ដែលតុលាការ Referral Bench បានច្រានចោលមិនយោងទៅរកតុលាការរបស់ បូស្នី និង ហឺហ្សេហ្គោវីន ដោយសារមិនមាន "ក្របខណ្ឌច្បាប់ពេញលេញដែលចែងជាបទល្មើសព្រហ្មទណ្ឌបានចំពោះការប្រព្រឹត្តិដែលគេចោទប្រកាន់ទៅលើជនជាប់ចោទ ថាអាចវិនិច្ឆ័យទោសនិងសម្រេចបាន និងក្របខណ្ឌច្បាប់ដែលចែងពីការផ្តន្ទាទោស"។

[54] Antonio Cassese, *International Criminal Law* (ឆ្នាំ២00៣), ទំព័រ ១៤១។

[55] Antonio Cassese, *International Criminal Law* (ឆ្នាំ២00៣), ទំព័រ ១៤១-១៤២។

និង ធាតុផ្សំអត្តនោមតិ”[56]។ ដូច្នេះ ទើបបុគ្គលទាំងឡាយអាចព្យាករណ៍ពីផលវិបាកនៃអំពើរបស់គេ ហើយអាចសម្រេចថាតើត្រូវគោរពតាម ឬត្រូវបំពានបទដ្ឋានច្បាប់ស្តីពីអំពើប្រព្រឹត្តបាន”[57]។

៥៩. “បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” មិនដែលបានក្លាយទៅជាកម្មវត្ថុនៃអនុសញ្ញាពិសេស[58]ណាមួយឡើយ ហើយការប៉ុនប៉ងទាំងឡាយដើម្បីកំណត់និយមន័យ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានទទួលបរាជ័យជាច្រើនលើក។ ចាប់តាំងពីការរៀបចំសេចក្តីព្រាងក្រមស្តីពីបទល្មើស ឆ្នាំ១៩៥៤ ដែលសេចក្តីព្រាងនោះមិនដែលត្រូវបានអនុម័ត រហូតដល់ពេលដែលមហាសន្និបាតឆ្នាំ ១៩៨១ បានសម្រេចឱ្យគណៈកម្មាធិការច្បាប់អន្តរជាតិបន្តធ្វើការលើសេចក្តីព្រាងក្រមស្តីពីបទល្មើស គ្មានអ្វីបានកើតឡើងឡើយ។ គេបានបញ្ជាក់ថា មុនពេលមានយុត្តិសាស្ត្រត្រូវបានសម្រេចឡើងដោយតុលាការពិសេស ស្តីពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋទាំងនេះស្ថិតនៅជា “ទស្សនទានអរូបី”[59]។ នេះមានន័យថា គ្មាននិយមន័យជាក់លាក់រឹងមាំនៃ “បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ” ត្រូវបានអនុម័តក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ រហូតមកទល់ពេលនោះ។ ដូច្នេះ ដើមបណ្តឹងឧទ្ធរណ៍មិនអាចទទួលបានព័ត៌មានអំពីនិយមន័យមនៃ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិបានទេ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ដើមបណ្តឹងឧទ្ធរណ៍គ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការព្យាករណ៍និងទទួលព័ត៌មានពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់តុលាការ។

*(២) និយមន័យនៃ “បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” របស់ កសចស បានបោះជំហានឆ្ងាយពីនិយមន័យ “បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” ដែលអាចត្រូវបានកំណត់ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩។*

---

[56] Antonio Cassese, *International Criminal Law* (ឆ្នាំ២០០៣), ទំព័រ ១៩៥។

[57] Antonio Cassese, *International Criminal Law* (ឆ្នាំ២០០៣), ទំព័រ ១៩៥។

[58] Cherif Bassiouni *Crimes Against Humanity in International Criminal Law* ទំព័រ៤១, ១៧៧ (Kluwer ឆ្នាំ១៩៩៩)។

[59] សូមមើល Guénaël Mettraux, *International Crimes and the Ad Hoc Tribunals* (ឆ្នាំ២០០៥), ទំព័រ១៤៧។

00615896



៦០. នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានយោងទៅរក និយមន័យនៃ "បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលត្រូវបានកំណត់ដោយលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក្នុងឆ្នាំ១៩៩៨[60] តែប៉ុណ្ណោះ។ ប៉ុន្តែ គេបានទទួលស្គាល់ថា "មាត្រា ៧ [នៃលក្ខន្តិកៈ ICC] បានឃ្លាតឆ្ងាយពីច្បាប់ទំនៀមទម្លាប់អន្តរជាតិតាមរយៈការកំណត់សញ្ញាណនៃ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យ៉ាងចម្លែកក្នុងអង្គច្បាប់មួយនេះ" [61] និងមានការទទួលស្គាល់ថានិយមន័យនោះបានពង្រីកធាតុផ្សំមួយចំនួន និងទម្រង់នៃអំពើប្រព្រឹត្តយ៉ាងទូលាយ" [62]។ និយមន័យដែលកំណត់ក្នុងលក្ខន្តិកៈ ICC មិនអាចព្យាករណ៍បាន និងផ្តល់ព័ត៌មានដល់ដើមបណ្តឹងឧទ្ធរណ៍ទេក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះត្រូវតែបដិសេធចោលនិយមន័យនេះ។

៦១. ឧទាហរណ៍ ទោះបីជាអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ត្រូវបានកំណត់ជាធាតុផ្សំនៃនិយមន័យដូចបានចែងក្នុងមាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធារអន្តរជាតិក្តី [63] ក៏សហចៅក្រមស៊ើបអង្កេតមិនបានប្រកាន់យកលក្ខខណ្ឌតម្រូវក្នុងនិយមន័យនៃ "បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលបានកំណត់ក្នុងដីកាដំណោះស្រាយឡើយ។ ដូចគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតបានដាក់បញ្ចូល "បទល្មើសរំលោភសេពសន្ថវៈ" ថាជាអំពើមួយក្នុងចំណោមបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ប៉ុន្តែ បទល្មើសរំលោភសេពសន្ថវៈ មិនត្រូវបានចាត់ទុកជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងលក្ខន្តិកៈតុលាការយោធារ គោលការណ៍ណ័ររឹមប៊ើក សេចក្តីព្រាងក្រមលើបទឧក្រិដ្ឋប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិឆ្នាំ១៩៥៤ ឬក្នុង CNASL[64] ឡើយ។ បន្ថែមលើនេះទៀត សហចៅក្រមស៊ើបអង្កេតបាន

---

[60] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបានអនុម័តឲ្យប្រើនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២។

[61] Antonio Cassese, *International Criminal Law* (ឆ្នាំ២០០៣), ទំព័រ៩៣។

[62] Cherif Bassiouni, *Crimes Against Humanity in International Criminal Law* (ឆ្នាំ១៩៩៩), ទំព័រ១៧៧-១៧៨។

[63] Cherif Bassiouni, *Crimes Against Humanity in International Criminal Law* (ឆ្នាំ១៩៩៩), ទំព័រ៧៧។

[64] 'ការរំលោភលើផ្លូវភេទ' ត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាលើកដំបូងនៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Akayesu*, សាលក្រម, សំណុំរឿងលេខ ICTR-96-4-T, ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦៨៧-៦៨៤។

បញ្ជាក់ថា ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ និយមន័យនៃ "បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" បានរាប់បញ្ចូលទាំង "អំពើអមនុស្សធម៌ផ្សេងទៀត រួមទាំងការរៀបការដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ" ផងដែរ។ មេធាវីការពារក្តីសូមបញ្ជាក់ថា ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ "អំពើអមនុស្សធម៌ផ្សេងទៀត" មិនបង្កើតបានជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ប្រភេទខុសគ្នានៃ "អំពើអមនុស្សធម៌" មិនមែនជាប្រភេទ "បទប្បញ្ញត្តិគ្របដណ្តប់ទាំងអស់"[65] ឡើយ។ មានមតិអះអាងថា ក្របខណ្ឌនៃការបកស្រាយលើ "អំពើអមនុស្សធម៌ផ្សេងទៀត" គប្បីប្រើឲ្យស្របទៅតាមបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដូចមានចែងក្នុងអនុសញ្ញាអន្តរជាតិនានា [66] ។ អនុលោមតាមក្របខណ្ឌនេះ មេធាវីការពារក្តីសូមបញ្ជាក់ថា ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ គ្មានអនុសញ្ញាអន្តរជាតិណាបានចាត់ទុកការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[67] អំពើហិង្សាផ្លូវភេទ[68] និងការបាត់ខ្លួនដោយបង្ខំ[69] ថាជាអំពើខុស

---

[65] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana*, សាលក្រម, សំណុំរឿងលេខ ICTR-95-1-T, ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩, កថាខណ្ឌ៥៨៣ និង ៥៨៦។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kordic និង Cerkez*, សាលដីកា, សំណុំរឿងលេខ IT-95-14/2-A, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤, កថាខណ្ឌ១១៧។

[66] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kupreskic និងអ្នកផ្សេងទៀត.*, សាលក្រម, សំណុំរឿងលេខ IT-96-16-T, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០, កថាខណ្ឌ៥៦៦។

[67] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេសស៊ីរ៉ាឡេអូន បានកត់សម្គាល់ថា នៅក្នុងបរិបទរបស់ប្រទេសស៊ីរ៉ាឡេអូន ការរៀបការដោយបង្ខំមានន័យដល់ *"អំពើអមនុស្សធម៌ផ្សេងៗ"* ដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងឆ្នាំ២០០៨។ សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត*, សាលក្រម, សំណុំរឿងលេខ SCSL-2004-16-A, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨, កថាខណ្ឌ១៩៦, ២០០-២០២។

[68] អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Akayesu* បានទទួលយកជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនូវការចោទប្រកាន់នៃ "អំពើអមនុស្សធម៌ផ្សេងៗ" នៅក្នុងបរិបទអំពើហិង្សារលើផ្លូវភេទ។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu*, សាលក្រម, សំណុំរឿងលេខ ICTR-96-4-T, ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨, កថាខណ្ឌ៦៩៧។

[69] ទើបតែឆ្នាំ១៩៩២ទេ ដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត "សេចក្តីប្រកាសស្តីពីការការពារជនទាំងឡាយពីការបាត់ខ្លួនដោយបង្ខំ "សេចក្តីប្រកាសស្តីពីការការពារបុគ្គលគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ" ដែលគ្មានអានុភាពភ្ជាប់កាតព្វកិច្ចមកលើរដ្ឋទាំងឡាយទេ។

ច្បាប់ឡើយ។ ពិសេសជាងនេះទៅទៀត កម្ពុជាគ្មានច្បាប់ជាតិដែលកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ "អំពើអមនុស្សធម៌" ក្នុងប្រភេទទាំងនេះឡើយ។

៦២. ដូច្នេះ សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការពង្រីកវិសាលភាពនៃអំពើដែលអាចបង្កើតបានជាបទល្មើសប្រឆាំងនឹងមនុស្សជាតិក្នុងក្របខណ្ឌពេលវេលាដែលពាក់ព័ន្ធ។ ការធ្វើបែបនេះមិនត្រឹមតែបំពានលើគោលការណ៍នីត្យានុកូលភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានន័យថាមិនបានបំពេញតាមលក្ខខណ្ឌជាក់លាក់នៃភាពអាចព្យាករណ៍បាន និងទទួលព័ត៌មានទៀតផង។

៦៣. ដូច្នេះ មេធាវីការពារក្ដីសន្និដ្ឋានថា ដើមបណ្ដឹងឧទ្ធរណ៍ មិនត្រូវរងការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដូចបានបញ្ជាក់ក្នុងដីកាដំណោះស្រាយនេះឡើយ។

## ៣.៥ ការរំលោភបំពានធ្ងន់ធ្ងរ

៦៤. ដីកាដំណោះស្រាយបានកំរិតការអនុវត្តបទរំលោភបំពានធ្ងន់ធ្ងរត្រឹម "មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខអូរកន្សែង និងក្នុងអំឡុងពេលកងទ័ពបដិវត្តកម្ពុជា [70] វាយចូលទៅក្នុងទឹកដីវៀតណាម ដូច្នេះការអនុវត្តបទល្មើសនេះក្នុងដីកាដំណោះស្រាយគឺមានកំរិត។ ការរំលោភបំពានធ្ងន់ធ្ងរគឺជាការបំពានជាក់លាក់លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ដែលតម្រូវមានជម្លោះប្រដាប់អាវុធជាអន្តរជាតិ និងទំនាក់ទំនងរវាងជម្លោះនេះនឹងការបំពានធ្ងន់ធ្ងរ [71] ។ ដោយសារតែបញ្ហានេះមិនស្ថិតក្នុងនីតិវិធីប្រឆាំងនឹងសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតថាមានជម្លោះប្រដាប់អាវុធក្នុងអំឡុងពេលទាំងស្រុងនៃយុត្តាធិការពេលវេលារបស់តុលាការនេះ ដោយសារបញ្ហានេះទាក់ទងនឹងសារធាតុនៃភ័ស្តុតាង មេធាវីការពារក្ដីរក្សាសិទ្ធិក្នុងការជំទាស់នឹងការសន្និដ្ឋាននោះក្នុងពេលជំនុំជម្រះលើអង្គសេចក្ដី។ លោក Dieter Fleck បានបញ្ជាក់ក្នុងអត្ថបទរបស់គាត់ស្ដីពីការរំលោភបំពានធ្ងន់ធ្ងរថា "ជម្លោះនៅកម្ពុជាបាន

[70] ដីកាដំណោះស្រាយ កថាខណ្ឌ១៤៧៩។

[71] Guénaël Mettraux, *International Crimes and the* Ad Hoc *Tribunals* (ឆ្នាំ២០០៥), ទំព័រ៥៤។

ក្លាយទៅជាជម្លោះអន្តរជាតិតែនៅដំណាក់កាលចុងក្រោយប៉ុណ្ណោះ ដែលដំណាក់កាលនេះកំរិតនៃភាពពាក់ព័ន្ធនៃ ការរំលោភបំពានធ្ងន់ធ្ងររបស់របបនេះ[72]។ ដូច្នេះ មេធាវីការពារក្តីសូមបញ្ជាក់ថា សេចក្តីសួដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ដែលអះអាងថាមានជម្លោះប្រដាប់អាវុធអន្តរជាតិនោះ [73] គឺមិនមាន មូលដ្ឋានគ្រប់គ្រាន់ ហើយជាសេចក្តីសន្និដ្ឋានឆាប់រហ័សពេក។

៦៥. លក្ខខណ្ឌតម្រូវបន្ថែមនៃការរំលោភបំពានធ្ងន់ធ្ងរ គឺមានន័យថាការប្រព្រឹត្តប្រឆាំងនឹងក្រុមជនដែលគេហៅថា "ប្រជាជនដែលត្រូវបានការពារ"។ សហចៅក្រមស៊ើបអង្កេត បានសម្រេចថាសមាជិកនៃកងកម្លាំងវៀតណាម ដែលបានធ្លាក់ទៅក្នុងកណ្តាប់ដៃនៃកងទ័ពបដិវត្តកម្ពុជា ថាជាឈ្លើយសឹកដែលត្រូវបានការពារ ដោយមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី III ហើយជនស៊ីវិលវៀតណាម ដែលបានធ្លាក់ទៅក្នុងកណ្តាប់ដៃនៃកងទ័ពបដិវត្តកម្ពុជា គឺជាជនស៊ីវិលដែលត្រូវបានការពារដោយមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី IV[74] ។ សហចៅក្រមស៊ើបអង្កេត មិនមានបំណងអនុវត្ត "លក្ខណៈវិនិច្ឆ័យនៃបុព្វហេតុ"ទេ[75]។

៦៦. មេធាវីការពារក្តីសូមបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការកំណត់ថា បទប្បញ្ញត្តិស្តីពីការរំលោភបំពានធ្ងន់ធ្ងរមានវិសាលភាពអនុវត្តចំពោះ អ.វ.ត.ក និងពឹងផ្អែកលើទឡ្ហីករណ៍ដែលបានចែងខាងលើក្នុងផ្នែក ៤.៣ ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

---

[72] Dieter Fleck, 'Shortcomings of the Grave Breaches Regime', នៅក្នុង: *Journal of International Criminal Justice* 7 (ឆ្នាំ២00៩), ទំព័រ៨៣៦។

[73] ដីកាដំណោះស្រាយ, ជំពូក VI, កថាខណ្ឌ១៥0 និងកថាខណ្ឌបន្តបន្ទាប់។

[74] ដីកាដំណោះស្រាយ កថាខណ្ឌ១៤៨១។

[75] សូមមើលចំពោះការពន្យល់នៃលក្ខណៈវិនិច្ឆ័យនេះ ដែលថាដីកាដំណោះស្រាយមិនបានកំណត់និយមន័យ, អត្ថបទរបស់ Dieter Fleck មានចំណងជើងថា 'Shortcomings of the Grave Breaches Regime', នៅក្នុង: *Journal of International Criminal Justice* 7 (ឆ្នាំ២00៩), ទំព័រ៨៤៣។

### ៣.៥.១ ការរំលោភបំពានធ្ងន់ធ្ងរមិនបានបង្កើតជាផ្នែកមួយនៃច្បាប់កម្ពុជាទេ

៦៧. មេធាវីការពារក្ដីសូមបញ្ជាក់ថា ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ មិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាទេក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលត្រូវបានទទួលស្គាល់យ៉ាងច្បាស់ថាជាក្រមព្រហ្មទណ្ឌដែលស្ថិតនៅជាធរមានក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពីឆ្នាំ១៩៧៥-១៩៧៩ [76] មិនមានបទប្បញ្ញត្តិណាមួយដែលចាត់ទុកការរំលោភបំពានធ្ងន់ធ្ងរជា បទល្មើសព្រហ្មទណ្ឌនៅក្នុងកម្ពុជាឡើយ។

៦៨. ការចោទប្រកាន់ដើមបណ្ដឹងឧទ្ធរណ៍ពីការរំលោភបំពានធ្ងន់ធ្ងរ គឺជាការបំពានលើគោលការណ៍នីត្យានុកូលភាព ដែលជាគោលការណ៍ដែលតម្រូវថា នឹងអាចផ្ដន្ទាទោសអំពើណាមួយបាន លុះត្រាតែអំពើនោះជាបទល្មើសដែលកំណត់ក្នុងច្បាប់ក្នុងពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត[77]។

៦៩. វាស្រដៀងគ្នាទៅនឹងបទបញ្ញត្តិនៃអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍, មាត្រា ១៤៦ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី៤ដែលតម្រូវឱ្យរដ្ឋជាភាគី "បង្កើតច្បាប់ណាមួយដែលចាំបាច់ដើម្បីបញ្ញត្តិឱ្យមានប្រសិទ្ធភាពក្នុងការផ្ដន្ទាទោសជនណាប្រព្រឹត្ត ឬ បានបញ្ជាឱ្យប្រព្រឹត្តនូវការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាបច្ចុប្បន្ននេះ"។ ប្រទេសកម្ពុជាខកខានមិនបានធ្វើដូច្នោះទេ ដែលជាលទ្ធផលនៅកម្ពុជាមានការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវនេះ។ ការខកខានបែបនេះបានរាំងកម្ពុជាមិនឱ្យអនុវត្តនូវយុត្តាធិការសាកលចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នេះ។

---

[76] អ.ប.ជ, សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧, កថាខណ្ឌ១៩។ សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ១៣០០។

[77] Antonio Cassese, *International Criminal Law* (ឆ្នាំ២០០៣), ទំព័រ១៤២។

## ៣.៥.២ ច្បាប់បង្កើត អ.វ.ត.ក មិនអាចបង្កើតច្បាប់ថ្មីបានទេ ហើយអនុវត្តច្បាប់ថ្មីដោយប្រតិសកម្មបានទេ

៧០. មេធាវីការពារក្តីសូមយោងទៅរកសេចក្តីសន្និដ្ឋានដែលចែងក្នុងផ្នែក ៣.៣.២ ខាងលើ ដែលអនុវត្តដូចគ្នា ចំពោះយុត្តាធិការទៅលើការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។ កិច្ចព្រមព្រៀងនិងច្បាប់បង្កើត អ.វ.ត.ក មិនអាចបង្កើតច្បាប់សារធាតុថ្មីដែលអាចយកមកអនុវត្តនៅក្នុងប្រព័ន្ធជាតិបានទេ។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនបានបញ្ចូលយុត្តាធិការសំរាប់ការបំពានធ្ងន់ធ្ងរនៅថ្នាក់ជាតិឡើយ។ មាត្រា ៦ នៃច្បាប់បង្កើត អ.វ.ត.ក គ្រាន់តែបានចែងថា អ.វ.ត.ក មានយុត្តាធិការលើបទឧក្រិដ្ឋ ប៉ុន្តែមិនបានបង្កើតយុត្តាធិការជាក់ស្តែងសម្រាប់ បទឧក្រិដ្ឋនោះឡើយ។ ដោយសារគ្មានមូលដ្ឋានណាផ្សេងក្នុងច្បាប់កម្ពុជាដែលពិតជាបានបង្កើតយុត្តាធិការនេះ ដូច្នេះ អ.វ.ត.ក គ្មានយុត្តាធិការដើម្បីចោទប្រកាន់ដើមបណ្តឹងឧទ្ធរណ៍ពីបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឡើយ។

## ៣.៥.៣ គ្មានការអនុវត្តការដោយផ្ទាល់នូវការរំលោភបំពានធ្ងន់ធ្ងរជាបទឧក្រិដ្ឋអន្តរជាតិឡើយ

៧១. មេធាវីការពារក្តីសូមយោងទៅរកសេចក្តីសន្និដ្ឋានដែលចែងក្នុងផ្នែក ៣.៣.៣ ខាងលើ ដែលអនុវត្តដូចគ្នាចំពោះយុត្តាធិការទៅលើការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។ដោយសារតែ អ.វ.ត.ក គឺជាផ្នែកនៃតុលាការជាតិដែលមានស្រាប់ ដូច្នេះ អនុសញ្ញាទីក្រុងហ្សឺណែវគ្មានអានុភាពអនុវត្តផ្ទាល់នៅក្នុងប្រព័ន្ធតុលាការជាតិឡើយ។ ក្នុងករណីណាក្តី ជាចាំបាច់ត្រូវតែមានការអនុម័តបញ្ចូលបទល្មើសរំលោភបំពានធ្ងន់ធ្ងរទៅក្នុងច្បាប់ជាតិក្នុងក្របខណ្ឌពេលវេលា ដោយមិនគិតថាកម្ពុជាប្រកាន់ប្រព័ន្ធឯកនិយម ឬទ្វិកនិយមឡើយ (សូមអានកថាខណ្ឌ ៣១-៣២ ខាងលើ)។ កម្ពុជាមិនបានធ្វើបែបនេះទេ ដូច្នេះ អ.វ.ត.ក គ្មានយុត្តាធិការលើបទឧក្រិដ្ឋប្រភេទនេះឡើយ។ ច្បាប់បង្កើត អ.វ.ត.ក មិនបានបង្កើតច្បាប់អនុវត្តដែលចាំបាច់សំរាប់ ក្នុងការបង្កើតយុត្តាធិការនេះឡើយ។

៧២. ដីកាដំណោះស្រាយមិនបានភ្ជាប់ទំនាក់ទំនងរវាងបទឧក្រិដ្ឋដែលបានចោទប្រកាន់ដែលអាចស្ថិតនៅក្នុងបទរំលោភបំពានធ្ងន់ធ្ងរ និងចោទប្រកាន់ថាដើមបណ្តឹងឧទ្ធរណ៍មានទំនាក់ទំនងទៅនឹងបទល្មើសនោះបានទេ។ ទោះបីយ៉ាងណាក្តី ពេលនេះមិនមែនជាពេលវេលាសមស្របក្នុងការលើកឡើងពីអង្គសេចក្តី

នៃការចោទប្រកាន់ពីការរំលោភបំពានធ្ងន់ធ្ងរនោះទេ ដូច្នេះ មេធាវីការពារក្តីសូមរក្សាសិទ្ធិលើកបញ្ហានេះក្នុងពេលសវនាការ។ ឥឡូវនេះមេធាវីការពារក្តីសូមអះអាងថា តាមមូលហេតុដូចបានបញ្ជាក់ខាងលើ អ.វ.ត.ក គ្មានយុត្តាធិការចោទប្រកាន់ដើមបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននេះបានឡើយ។

## ៣.៦ បទឧក្រិដ្ឋជាតិ

៧៣. មេធាវីការពារក្តីបានបញ្ជាក់ខាងលើថា អង្គបុរេជំនុំជម្រះគប្បីប្រកាសផ្នែកនៃដីកាដំណោះស្រាយដែលទាក់ទងទៅនឹងការចោទប្រកាន់អំពីបទល្មើសជាតិដែលចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទុកជាអសារឥតការ។ម្យ៉ាងវិញទៀត មេធាវីការពារក្តីសូមអះអាងថា អ.វ.ត.ក គ្មានយុត្តាធិការចោទប្រកាន់ដើមបណ្តឹងឧទ្ធរណ៍ពីបទល្មើសទាំងនេះឡើយ។

៧៤. ក្នុងរឿងក្តីឌុច ចៅក្រមអង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចតាមសម្លេងភាគច្រើនលើករណីនេះទេ ហើយក៏មិនអាចចោទប្រកាន់ឌុចពីបទល្មើសជាតិទាំងនេះដែរ[78]។ សហព្រះរាជអាជ្ញាមិនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះទេ ដោយសារពួកគេបានយល់ស្របតាមការរកឃើញផ្លូវច្បាប់បែបនេះ។ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាតាមវិធាន ៦៦[79] មិនបានយោងទៅរកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ នេះទេ ហើយសហព្រះរាជអាជ្ញាមិនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះទេ។ សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការសន្និដ្ឋានរបស់ពួកគេអំពីយុត្តាធិការនៃប្រភេទបទល្មើសទាំងនេះ ដោយមិនបានយោងទៅរកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តីឌុច។

---

[78] អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើអញ្ញត្តិកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, សំណុំរឿងលេខ ០០១ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187។

[79] សេចក្តីសន្និដ្ឋានស្ថាពរ របស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៦៦, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០, ឯកសារ D390។

៧៥. ក្នុងរឿងក្តីខុច អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ស្ថិតនៅជាធរមាន ក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក [80] ។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានចែងពី អាជ្ញាយុកាល ហើយអាជ្ញាយុកាលនេះបានហាមឃាត់មិនឱ្យមានការចោទប្រកាន់បទឧក្រិដ្ឋដែលចែង ក្នុងច្បាប់នេះ ក្រោយរយៈពេលដប់ឆ្នាំគិតចាប់ពីពេលនៃការប្រព្រឹត្តបទល្មើស[81]។

៧៦. មាត្រា ៣ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា "អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យារពេលបន្ថែម ៣០ឆ្នាំទៀត ទៅលើ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំ ជម្រះវិសាមញ្ញ"។

៧៧. មេធាវីការពារក្តីសូមបញ្ជាក់ថាការចោទទ្រកាន់ពីបទឧក្រិដ្ឋកម្មជាតិ ត្រូវបានហាមឃាត់ដោយច្បាប់ អាជ្ញាយុកាល ហើយការពន្យារអាជ្ញាយុកាលដែលអនុញ្ញាតឱ្យមានការចោទប្រកាន់ គឺជាការបំពាន លើគោលការណ៍ទូទៅស្តីពី*នីតិព្រហ្មទណ្ឌ: គ្មានបទល្មើសបើគ្មានច្បាប់ចែង*។ ប្រការគួរឱ្យចាប់ អារម្មណ៍គឺ មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ខ្លួនឯង ហាមឃាត់ការអនុវត្តច្បាប់ប្រតិសកម្ម។

៧៨. មេធាវីការពារក្តីសូមបញ្ជាក់ថាគោលការណ៍ទូទៅមួយទៀតស្តីពីច្បាប់ព្រហ្មទណ្ឌចែងថា ច្បាប់ព្រហ្ម ទណ្ឌត្រូវតែកំណត់ឱ្យបានច្បាស់សម្រាប់សាធារណជន ហើយមិនត្រូវកំណត់ទិសដៅចំពោះបុគ្គលមួយ ក្រុមជាក់លាក់ឡើយ។ មាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាការបំពានលើគោលការណ៍ នេះ ហើយក៏ជាការបំពានលើសិទ្ធិស្មើភាពគ្នារបស់ដើមបណ្តឹងឧទ្ធរណ៍ ដែលការពន្យារអាជ្ញាយុកាល អនុវត្តចំពោះតែការចោទប្រកាន់ចំពោះបុគ្គលនៅចំពោះមុខ អ.វ.ត.ក ក្នុងករណីដែលពួកគេរងការ

---

[80] ការជម្រាបជូនអំពីក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងសំណើសុំផ្តល់ការបញ្ជាក់លើក្រមផ្លូវការ សំណុំរឿងលេខ០០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ E91/5។

[81] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា១០៩។

00615904



ចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ហើយច្បាប់មិនបានពន្យារអាជ្ញាយុកាលចំពោះបទល្មើសស្រដៀងគ្នាទាំងអស់ ដែលបានប្រព្រឹត្តនៅចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ២០០៣។ ដូច្នេះ ច្បាប់ដែលបានកំណត់ឡើងសំរាប់តែបុគ្គលមួយក្រុមជាក់លាក់នោះ ហើយមិនមែនសំរាប់សាធារណជនទូទៅនោះគឺជាការរំលោភបំពានលើគោលការណ៍ទូទៅស្តីពីសិទ្ធិស្មើភាពគ្នាក្នុងរឿងក្តីដូចគ្នា។ ការធ្វើបែបនេះគឺជាការរើសអើងប្រឆាំងនឹងដើមបណ្តឹងឧទ្ធរណ៍។

៧៩. អង្គបុរេជំនុំជម្រះ ត្រូវតែបដិសេធចោលការអនុវត្តមាត្រា ៣ថ្មី ដោយផ្អែកលើមូលដ្ឋានទាំងនេះ។

## ៣.៧ សហឧក្រិដ្ឋកម្មរួម

៨០. នៅដំណាក់កាលដំបូងនៃនីតិវិធីស៊ើបសួរ មេធាវីការពារក្តីបានលើកឡើងនូវបញ្ហានៃការគ្មានយុត្តាធិការលើសហឧក្រិដ្ឋកម្មរួម (JCE)[82]។ អង្គបុរេជំនុំជម្រះក៏បានសម្រេចលើបញ្ហានេះ ហើយបានរកឃើញថា អាចអនុវត្តសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខ អ.វ.ត.ក បាន លើកលែងតែប្រភេទទម្រង់ពង្រីក។ ដូច្នេះ បញ្ហានេះត្រូវបានតទល់គ្នារួចហើយនៅចំពោះមុខអង្គជំនុំជម្រះនេះ។ មេធាវីការពារក្តីមានចេតនាជំទាស់ការអនុវត្តទ្រឹស្តីនេះ នៅក្នុងសវនាការបឋមរបស់អង្គជំនុំជម្រះសាលាដំបូង ហើយមិនទាន់ជំទាស់ក្នុងបណ្តឹងឧទ្ធរណ៍នៅពេលនេះទេ។

## ៣.៨ ការទទួលខុសត្រូវរបស់ថ្នាក់លើ

---

[82] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ ចំពោះ "ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម" នៃថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០, ឯកសារ D97/15/1 និង សាលដីការរបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០, ឯកសារ D97/15/9។

៨១. ដីកាដំណោះស្រាយបានចោទប្រកាន់ដើមបណ្ដឹងឧទ្ធរណ៍ពីការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវ ដែលទាក់ទងទៅនឹងបទឧក្រិដ្ឋកម្មបីដែលកំណត់នៅក្នុង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[83]។

ក) អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ការវាយប្រហារលើភាពថ្លៃថ្នូររបស់មនុស្ស និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

ខ) ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

គ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម។

៨២. ដើមបណ្ដឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ថា "បានខកខានខ្វះកាតព្វកិច្ចក្នុងការចាត់វិធានការចាំបាច់នានា ដើម្បីបង្ការឧក្រិដ្ឋកម្មទាំងនេះ" ហើយ "ម្យ៉ាងទៀត អៀង ធីរិទ្ធ បានដឹង ឬមានហេតុផលដឹងថា ឧក្រិដ្ឋកម្មទាំងនេះពិតជាត្រូវបានប្រព្រឹត្តយ៉ាងជាក់ស្ដែង ដោយអ្នកក្រោមបង្គាប់របស់ខ្លួន ហើយខ្លួនបានខកខានមិនបានដាក់ទោសទៅលើចារីទាំងនោះ"[84] ។

៨៣. ក្នុងរឿងក្ដីខុច អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តយុត្តាធិការ ទៅលើទ្រឹស្ដីនៃការទទួលខុសត្រូវរបស់ថ្នាក់លើដោយមិនបានវាយតម្លៃទៅលើការជំទាស់ដែលមានសក្ដានុពលទៅនឹងបញ្ហានេះទេ [85] ដែលមេធាវីការពារក្ដីសន្និដ្ឋានថា មេធាវីការពារខុច មិនបានលើកបញ្ហានេះមកជំទាស់ទេ។ ទោះជាយ៉ាងណាក្ដី មានការជំទាស់ជាច្រើនខាងយុត្តាធិការ ទៅលើទម្រង់នៃការទទួលខុសត្រូវនេះ ដែលមេធាវីការពារក្ដីសូមលើកឡើងដូចខាងក្រោមនេះ។

## ៣.៨.១ <u>ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ</u>

---

[83] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៦១។

[84] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦២។

[85] សាលក្រម ឌុច, ផ្នែក២.៧.១០ ទំព័រ១៨៦។

៨៤. ក្នុងច្បាប់អន្តរជាតិ គ្មានមូលដ្ឋានទំនៀមទម្លាប់ ដែលគាំទ្រការអនុវត្តទ្រឹស្តីនេះទេ ក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ហើយនៅក្នុងដីកាដំណោះស្រាយ កសចស ក៏មិនបានផ្តល់មូលដ្ឋាន គាំទ្រនូវការអនុវត្តនេះទេ។ ដូច្នេះ ការចោទប្រកាន់ពីការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាការរំលោភបំពានលើគោលការណ៍ដែលថាគ្មានបទល្មើសបើគ្មានច្បាប់ចែង ដូច្នេះមេធាវីការពារក្តីគោរពស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលផ្នែកនេះនៃដីកាដំណោះស្រាយត្រង់ចំណុចដែលមានការបំពាននេះ។

៨៥. ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានបង្កើតឡើងជាលើកដំបូងក្នុងរឿងក្តី Yamashita ដោយគណៈកម្មាធិការយោធាអាមេរិក ក្នុងទីក្រុងម៉ានីល ក្នុងឆ្នាំ១៩៤៥[86]។ លោក Mettraux បានបញ្ជាក់ថា វាអាចជាកំហុសមួយក្នុងការសន្និដ្ឋានថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ បង្កើតបានជាផ្នែកនៃទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៤៥ លោកបានព្រមានថា "ករណីយុត្តិសាស្ត្ររឿងក្តី Yamashita គឺជាសេចក្តីសម្រេចក្នុងប្រវត្តិសាស្ត្រច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលជាការព្រមានប្រឆាំងនឹងការប៉ុនប៉ងធ្វើច្បាប់ដែលគ្មានការកំហិត ដើម្បីឱ្យសាកសមទៅនឹងលទ្ធផលដែលតុលាការចង់បាន"[87]។ គាត់បានបញ្ជាក់បន្ថែម ដោយដកស្រង់ពីគណៈកម្មាធិការឧក្រិដ្ឋសង្គ្រាមរបស់ អ.ស.ប ដែលចែង ក្នុងឆ្នាំ១៩៤៨ ថា "គោលការណ៍ដែលគ្រប់គ្រងការទទួលខុសត្រូវ [របស់ថ្នាក់លើ] ... មិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ"[88]។

៨៦. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានទទួលស្គាល់ឋានៈនៃទម្លាប់អន្តរជាតិ ស្តីពីទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដែលបានសម្រេចថា "គោលការណ៍ដែលថា

---

[86] ការជំនុំជម្រះក្តី Tomoyuki Yamashita, គណៈកម្មការយោធាអាមេរិក, Manila, និង តុលាការកំពូលសហរដ្ឋអាមេរិក, ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៤៦, អាចរកបាននៅ៖ http://www.ess.uwe.ac.uk/wcc/yamashita1.htm ។

[87] Guénaël Mettraux, *The Law of Command Responsibility* (ឆ្នាំ២០០៩), ទំព័រ៧-៨។

[88] Guénaël Mettraux, *The Law of Command Responsibility* (ឆ្នាំ២០០៩), ទំព័រ១៣។

ឃោធា និងថ្នាក់លើជទៃទៀត អាចមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់អ្នកក្រោមបញ្ជារបស់ពួកគេ លុះត្រាតែទ្រឹស្តីនោះត្រូវបានបង្កើតត្រឹមត្រូវដោយអនុសញ្ញា និងទម្លាប់អន្តរជាតិ។ បទដ្ឋាននៃការត្រួតពិនិត្យត្រូវបានចែងក្នុងមាត្រា ៨៧(៣) នៃពិធីសារបន្ថែមទី I អាចត្រូវបានចាត់ទុកថាមានលក្ខណៈជាទំនៀមទម្លាប់" ដោយសំដៅទៅលើអង្គហេតុថា ក្នុងឆ្នាំ១៩៩២ មានរដ្ឋចំនួន ១១៩ បានធ្វើសច្ចាប័នលើពិធីសារនេះ [89] ។ ប៉ុន្តែពិធីសារនេះទើបតែបានបង្កើតឡើងក្នុងឆ្នាំ១៩៧៧ នេះទេ។ នៅចំណុចចាប់ផ្តើមនៃយុត្តាធិការពេលវេលារបស់តុលាការនេះ ពិធីសារនេះមិនទាន់មានអត្ថិភាពនៅឡើយទេ ហើយជាពិសេសទៅទៀត នៅដើមឆ្នាំ១៩៧៩ មានរដ្ឋតែបីទេ ដែលបានធ្វើសច្ចាប័នលើពិធីសារបន្ថែមទី I នេះ។ រដ្ឋភាគច្រើនគ្រាន់តែបានប្រកាសទទួលស្គាល់ពិធីសារនេះ ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និង ១៩៩០[90] ប៉ុណ្ណោះ។ សេចក្តីសង្កេតរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ថាវិធាននៃទម្លាប់អន្តរជាតិបែបនេះបានមានអត្ថិភាពមុនការអនុម័តពិធីសារបន្ថែមទី I[91] នោះគឺគ្មានភ័ស្តុតាងណាមួយគាំទ្រឡើយ ហើយក៏គ្មានច្បាប់យុត្តិសាស្ត្រដែលចែងបង្កើតទម្លាប់របស់រដ្ឋ និងមតិយោបល់ចៅក្រមអំពីឋានៈនៃទម្លាប់អន្តរជាតិនេះឡើយ។

---

[89] សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Delalic* និងអ្នកផ្សេងទៀត, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, សំណុំរឿងរឿងលេខ IT-96-21-A, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១, កថាខណ្ឌ១៩៥។ សូមមើល៖ http://www.icrc.org/IHL.nsf/(SPF)/party_main_treaties/$File/IHL_and_other_related_Treaties.pdf ។

90 មានតែ El Salvador, Ghana និង Libya ទេដែលឲ្យសច្ចាប័នពិធីសារបន្ថែម I, សូមមើល៖ http://www.icrc. នៅក្នុងឆ្នាំ១៩៧៨ org/IHL.nsf/(SPF)/party_main_treaties/$File/IHL_and_other_related_Treaties.pdf ។

[91] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Hadzihasanovic* និងអ្នកផ្សេងទៀត, Aអង្គជំនុំជម្រះតុលាការកំពូល, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំប្រឆាំងនឹងយុត្តាធិការ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ, សំណុំរឿងលេខ IT-01-47-AR72, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣, កថាខណ្ឌ២៩។

៨៧. នៅក្រោយសម័យសង្គ្រាមលោកលើកទីពីរ រហូតដល់ការអនុវត្តទ្រឹស្តីនេះនៅតុលាការ ICTY និងតុលាការ ICTR នៅដើមសតវត្សរ៍នេះ ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ កម្រត្រូវបានគេយកមកអនុវត្តណាស់។ Mettraux ក៏បានលើកឡើងថា ការវិវឌ្ឍសំខាន់ៗបំផុតៗនៅក្នុងសម័យនេះ គឺការបង្កើតមាត្រា ៨៦ និងមាត្រា ៨៧ នៃពិធីសារបន្ថែម I [៩២]។ ដូចបានលើកឡើងខាងលើ មាត្រាទាំងនេះ មិនចងកាតព្វកិច្ចដល់ប្រទេសកម្ពុជានៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនោះទេ ហើយក៏មិនបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងពេលវេលាដែលពាក់ព័ន្ធដែរ។ គឺមានតែយុត្តិសាស្ត្រដែលលេចចេញពីតុលាការ ICTY និង តុលាការ ICTR ប៉ុណ្ណោះ ដែលបានជម្រុញប្រព័ន្ធយុត្តាធិការជាតិឱ្យធ្វើការចោទប្រកាន់ ដោយផ្អែកលើមូលដ្ឋាននៃមាត្រាទាំងនេះ[៩៣]។

៨៨. គេមិនឃើញមានយុត្តិសាស្ត្រមុនៗ ដែលគាំទ្រលើការរកឃើញថា ការទទួលខុសត្រូវរបស់ថ្នាក់លើ បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅមុនអំឡុងពេលនោះ ដោយយើងពុំចាំបាច់គិតដល់យុត្តាធិការលើពេលវេលារបស់តុលាការនេះនៅចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩ឡើយ។

៨៩. ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធឡើយ ពោលគឺនៅពេលដែលបទល្មើស ដូចដែលបានចោទប្រកាន់បានប្រព្រឹត្តឡើយ។ ហេតុដូច្នេះហើយ ដើមបណ្តឹងឧទ្ធរណ៍មិនអាចត្រូវបានគេចោទប្រកាន់ពីទម្រង់នៃការទទួលខុសត្រូវមួយនេះឡើយ។

៣.៨.២ <u>ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចអនុវត្តទៅបានចំពោះឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ។</u>

៩០. ជាជម្រើសមួយផ្សេងវិញ ក្រុមមេធាវីការពារក្តីសន្និដ្ឋានថា នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចត្រូវបានគេយកមកចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ។

---

[92] Guénaël Mettraux, *The Law of Command Responsibility* (ឆ្នាំ២០០៩), ទំព័រ១៣, ជើងទំព័រ២។

[93] Guénaël Mettraux, *The Law of Command Responsibility* (ឆ្នាំ២០០៩), ទំព័រ១៤។

៩១. នៅពេលបង្កើតទ្រឹស្តីនេះឡើងក្រោយសង្គ្រាមលោកលើកទី II ទ្រឹស្តីនៃការទទួលខុសត្រូវរបស់មេបញ្ជាការ អាចអនុវត្តទៅបានចំពោះការចោទប្រកាន់លើឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ [៩៤] ។ នេះនៅតែជាជំហរមួយ រហូតទាល់តែតុលាការ ICTY បានសម្រេចថា ការទទួលខុសត្រូវរបស់មេបញ្ជាការ ក៏អាចភ្ជាប់នឹងបទល្មើស អន្តរជាតិដទៃៗទៀត ដែលតុលាការ ICTY មានយុត្តាធិការលើបទល្មើសទាំងនេះ [៩៥] ។ វាក៏បានពង្រីក នូវវិសាលភាពនៃការទទួលខុសត្រូវរបស់មេបញ្ជាការលើជម្លោះប្រដាប់អាវុធក្នុងស្រុកផងដែរ [៩៦] ។ ទោះបីជា យ៉ាងនេះក្តី ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា វិធានច្បាប់ទំនៀមទម្លាប់មិនមានអត្ថិភាពនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ដែលអនុញ្ញាតឱ្យមានការចោទប្រកាន់ការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ។

៩២. ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវជាថ្នាក់លើចំពោះឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ មិនមែនឧក្រិដ្ឋកម្មសង្គ្រាម ឬការរំលោភបំពានធ្ងន់ធ្ងរឡើយ [៩៧] ។ ហេតុដូច្នេះ តុលាការមិនមានយុត្តាធិការ ចោទប្រកាន់លោកស្រីពីការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានចោទប្រកាន់ នោះឡើយ។

### ៣.៨.៣ អនុវត្តដោយកម្រិតលើការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះជនស៊ីវិល

៩៣. ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ គឺផ្អែកលើមូលដ្ឋាននៃការខកខានមិនបានចាត់ វិធានការ។ ដូច្នេះ កាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការរារាំងការប្រព្រឹត្តបទល្មើសចាំបាច់ត្រូវមានអត្ថិភាព [៩៨] ។ ដីកាដំណោះស្រាយ ខកខានមិនបានបង្ហាញអំពីអំពីកាតព្វកិច្ចបែបនេះ។ នៅពេលពិចារណាលើការទទួលខុសត្រូវរបស់ថ្នាក់លើ

---

[94] សូមមើល Yael Ronen, 'Superior Responsibility of Civilians for International Crimes Committed in Civilian Settings', នៅក្នុង៖ *Vanderbilt Journal of Transnational Law* 43:313 (ឆ្នាំ២០១០), ត្រង់ទំព័រ ៣៣១។

[95] មាត្រា៧(៣) នៃលក្ខន្តិកៈតុលាការ ICTY ។

[96] សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Hadzihasanovic* និងអ្នកផ្សេងទៀត, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា លើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ប្រឈមទៅនឹងយុត្តាធិការពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់មេបញ្ជាការ សំណុំរឿងលេខ IT-01-47-AR72, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៣១។

[97] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦១។

[98] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Oric*, សាលក្រម, សំណុំរឿងលេខ IT–03–68–T, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦, កថាខណ្ឌ៣២៦។

ចំពោះជនស៊ីវិល តុលាការ ICTR ក៏បានពិចារណាលើច្បាប់ជាតិ ដែលអនុវត្តចំពោះថ្នាក់លើ។ នៅក្នុងរឿងក្តី Kayishema អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានសម្រេចថា "ដោយពិនិត្យមើលកាតព្វកិច្ចតាម [ច្បាប់ជាតិ] ដែលត្រូវរក្សាសណ្តាប់ធ្នាប់សាធារណៈ [...] Kayishema មានកាតព្វកិច្ចធានាយ៉ាងណាកុំឱ្យកូនចៅក្រោមបង្គាប់របស់ខ្លួនធ្វើការវាយប្រហារលើជនជាតិទូស៊ី ដែលជនជាតិទាំងនេះបានរត់ជ្រកកោននៅក្នុងព្រះវិហារ Muguba"[៩៩]។ Ronen លើកឡើងទាក់ទងនឹងចំណុចនេះថា "ច្បាប់ព្រហ្មទណ្ឌអន្តរជាតិជាប្រព័ន្ធច្បាប់ ដែលមានលក្ខណៈដោយឡែកមួយ និងខុសប្លែកពីច្បាប់ជាតិ ហើយកាតព្វកិច្ចនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិលើករណីណាមួយនោះ មិនជ្រៀតចូលនៅក្នុងច្បាប់ជាតិឡើយ"[១០០]។ នៅពេលខកខានមិនបានបង្ហាញអំពីអត្ថិភាពនៃ កាតព្វកិច្ចបែបនេះ និងមូលដ្ឋានរបស់វានៅក្នុងច្បាប់ជាតិ សហចៅក្រមស៊ើបអង្កេត មិនបាន ផ្តល់មូលដ្ឋានមួយលើការចោទប្រកាន់លើការទទួលខុសត្រូវជាថ្នាក់លើរបស់ដើមបណ្តឹងឧទ្ធរណ៍ ក្នុងនាមជនត្រូវចោទជារដ្ឋមន្ត្រីសង្គមកិច្ចឡើយ។ ការដែលមិនបានផ្តល់មូលដ្ឋានដូច្នេះ វាបានធ្វើឱ្យបទចោទលើទម្រង់នៃការទទួលខុសត្រូវនេះមោឃៈ ហេតុដូច្នេះ ដីកាដំណោះស្រាយគួរតែបដិសេធចោលលើករណីនេះ។

## ៣.៩ សេចក្តីសន្និដ្ឋាន

៩៤. ដោយសារមានហេតុផលទាំងនេះ ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការចោទប្រកាន់ជនត្រូវចោទពីបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ដូចបានពិភាក្សាខាងលើឡើយ។ ហេតុដូច្នេះក្រុមមេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវផ្នែកទាំងនោះនៅក្នុងដីកាដំណោះស្រាយទៅតាមនេះ។

## IV. ការរំលោភសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌

### <u>៤.១ ដីកាដែលពុំមានសំអាងហេតុគ្រប់គ្រាន់ គឺជាការធ្វើឡើងតាមទំនើងចិត្ត</u>

---

[99] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema*, សាលក្រម, ICTR-95-1-T, ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩, កថាខណ្ឌ៥១០។

[100] Yael Ronen, 'Superior Responsibility of Civilians for International Crimes Committed in Civilian Settings', នៅក្នុង៖ *Vanderbilt Journal of Transnational Law* 43:313 (ឆ្នាំ២០១០), ទំព័រ៣៣៤។

៩៥. អនុលោមតាមវិធាន ៦៧(៥)នៃវិធានផ្ទៃក្នុង "ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ"។ ក្រុមមេធាវីការពារក្តីសន្និដ្ឋានថា ផ្នែកមួយចំនួននៅក្នុងដីកាដំណោះស្រាយ បានរំលោភបំពានលើបទប្បញ្ញត្តិនេះ។ ក្រុមមេធាវីការពារក្តីសូមលើកឡើងថា អង្គបុរេជំនុំជម្រះគួរយកសំអាងហេតុរបស់ខ្លួនលើធាតុជាក់លាក់ទាំងនេះនៅក្នុងដីកាដំណោះស្រាយ មកជំនួសលើការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។ ក្រុមមេធាវីការពារក្តី ធ្វើការកម្រិតខ្លួនឯង ដោយមិនបានផ្តល់សំអាងឱ្យបានគ្រប់គ្រាន់ចំពោះបញ្ហាយុត្តាធិការនៅក្នុងករណីនេះ។

៩៦. នៅពេលលើកឡើងអំពីការសម្រេចតាមផ្លូវច្បាប់របស់ខ្លួនលើបទល្មើសទាំងឡាយ និង ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងដីកា ដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានយោងលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តី *ឌុច* (រឿងក្តីលេខ 00១) តែប៉ុណ្ណោះ [១០១]។ ឧទាហរណ៍អាចមើលឃើញនៅក្នុងកថាខណ្ឌ ១៣១៨ នៅក្នុងដីកាដំណោះស្រាយ ដែលសហចៅក្រមស៊ើបអង្កេតសម្រេចថា "ទម្រង់នៃការទទួលខុសត្រូវទាំងអស់ ដែលមានរៀបរាប់នៅក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក សុទ្ធតែត្រូវបានទទួល ស្គាល់ដោយច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជាក្នុងពេលដែលអង្គហេតុបានកើតឡើង"។ លេខយោង ជើងទំព័រ ៥២១៤ គ្រាន់តែយោងទៅលើកថាខណ្ឌ ៤៧២ និងកថាខណ្ឌបន្តបន្ទាប់នៅក្នុងសាលក្រម *ឌុច* តែប៉ុណ្ណោះ។ នៅក្នុងផ្នែកស្តីពីការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សហចៅក្រមស៊ើបអង្កេត បានសន្និដ្ឋានដូចតទៅថា៖ "នៅគ្រប់ពេលទាំងអស់ ចារីនៃឧក្រិដ្ឋកម្មបានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់ អាវុធអន្តរជាតិ និងដឹងអំពីកាលៈទេសៈនៃអង្គហេតុដែលបានបង្ហាញឱ្យឃើញពីស្ថានភាពនៃការការពាររបស់ជនរងគ្រោះ" [១០២]។ លេខយោងជើងទំព័រទាំងពីរដែលពាក់ព័ន្ធនឹងព័ត៌មាននេះ លេខយោជើងទំព័រ ៥២៨០ និងលេខយោងជើងទំព័រ៥២៨១ យោងលើសាលក្រម *ឌុច* និងសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ ICTY នៅក្នុងរឿងក្តី *Naletilic* និង *Martinovic*។ យើងមិនឃើញមានយោងលើអង្គហេតុ ដែលគួសបញ្ជាក់អំពីរឿងក្តីយើងនេះ សូម្បីតែមួយក៏គ្មានដែរ។ នៅពេលមិនមានការពន្យល់បន្ថែមដូច្នេះ សហចៅក្រមស៊ើបអង្កេតយោងលើសេចក្តីពិចារណា និងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនៅ ក្នុងរឿងក្តីដោយឡែកមួយនៅ អ.វ.ត.ក។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងពេលមួយចំនួន សហចៅក្រមស៊ើបអង្កេតបានពិចារណា និងសម្រេចផ្ទុយពីសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង នៅត្រង់កន្លែងណាដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចចេញសេចក្តីសម្រេច

---

[101] សាលក្រមអង្គជំនុំជម្រះសាលាដំបូង សំណុំរឿងលេខ00១/១៨-0៧-២00៧/អ.វ.ត.ក/អ.ជ.ស.ឌ (សំណុំរឿង00១), ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២0១0, ឯកសារ E188 (សាលក្រម ឌុច)។

[102] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៨៧, ជើងទំព័រ ៥២៨0 និង៥២៨១ ត្រូវបានលុប។

របស់ខ្លួនដោយផ្អែកតាមសំឡេងភាគច្រើន លើសលុបបានចំពោះការចោទប្រកាន់លើបទល្មើសជាតិ ដែលជាហេតុមិនអាចចោទប្រកាន់ ឌុច លើប្រភេទនៃបទល្មើសនេះ។ ទោះបីជាយ៉ាងនេះក្តី សេចក្តីសម្រេចនោះមិនត្រូវបានភាគីធ្វើការប្តឹងឧទ្ធរណ៍ឡើយ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបែរជាសម្រេចផ្ទុយពីសេចក្តីសម្រេចស្ថាពររបស់អង្គជំនុំជម្រះសាលាដំបូងទៅវិញ[១០៣]។

៩៧. សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់មូលដ្ឋានភ័ស្តុតាងដោយមានសំអាងហេតុ ដើម្បីគាំទ្រលើសេចក្តីសម្រេចរបស់ខ្លួន ដែលខ្លួនបានទទួលស្គាល់នូវការរកឃើញច្បាប់មួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបែរជាមិនរវីរវល់នឹងការរកឃើញអង្គច្បាប់ផ្សេងៗទៀត។ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបបានបញ្ជាក់ច្បាស់ថា “សំអាងហេតុគឺមានលក្ខណៈចាំបាច់ចំពោះគុណភាពនៃយុត្តិធម៌ ហើយសំអាងហេតុផ្តល់ការការពារមិនឲ្យមានការធ្វើឡើងតាមអំពើចិត្ត”។ គោលការណ៍នេះត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាសម្រេចនាពេលថ្មីៗលើបណ្តឹងឧទ្ធរណ៍ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរមួយចំនួន [១០៤]។ វាអាចបង្ហាញថា នៅក្នុងពេលជាច្រើន សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់មូលដ្ឋានភ័ស្តុតាងដោយមានសំអាងហេតុចំពោះការសន្និដ្ឋានទាំងឡាយនៅក្នុងដីកាដំណោះស្រាយឡើយ។

## ៤.២ ការរកឃើញអង្គច្បាប់មិនអាចចម្លងយកមកដាក់ដោយមិនផ្តល់សំអាងហេតុឲ្យបាន សមរម្យឡើយ

៩៨. ក្រៅពីបញ្ហានៃការធ្វើឡើងតាមទំនើងចិត្ត ក្រុមមេធាវីការពារក្តីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេត មានការភ័ន្តច្រឡំ នៅពេលខកខានមិនបានយកអង្គហេតុជាក់លាក់នៅក្នុងរឿងក្តី ដែលដាក់បន្ទុកលើដើមបណ្តឹងឧទ្ធរណ៍នេះមកអនុវត្តចំពោះបញ្ហាទាំងឡាយដែលត្រូវសម្រេចឡើយ។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានយោងលើការរកឃើញអង្គហេតុដែលទទួលស្គាល់រួចហើយដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *ឌុច*

---

[103] សូមមើល ជំពូក VII – ឧក្រិដ្ឋកម្មដែលត្រូវផ្តន្ទាទោសក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦, ដីកាដំណោះស្រាយ កថាខណ្ឌ៣៨៦-៣៨៩ និងសូមមើល អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, សំណុំរឿងលេខ 00១ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 ។

[104] អ.ប.ជ, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង “ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ” ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D353/2/3, កថាខណ្ឌ២៦, ដកស្រង់ពីរឿងក្តី *Taxquet តទល់នឹង Belgium*, តុលាការ ECHR, បណ្តឹងលេខ 926/05, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩, កថាខណ្ឌ៥០។

តែប៉ុណ្ណោះ ដែលរឿងក្តីនេះមានលក្ខណៈខុសពី និងដាច់ដោយឡែកពីរឿងក្តីនេះ។ បន្ថែមពីនេះ វានឹងមិនមានភាពយុត្តិធម៌ឡើយ ប្រសិនបើអនុវត្តតាមវិធិសាស្ត្រនេះ នៅពេលដែលក្រុមមេធាវីការពារក្តីនៅក្នុងរឿងក្តីលេខ 00២ មិនត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានលើអង្គច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធី ដែលមានការធ្វើការសន្និដ្ឋានលើអង្គច្បាប់។ វាបានបង្ហាញថា បញ្ហាអង្គហេតុទាក់ទងនឹងដើមបណ្តឹងឧទ្ធរណ៍នីមួយៗ មិនត្រូវបានយកមកពិចារណា នៅមុនពេលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើបញ្ហាទាំងនេះនោះទេ[១០៥]។ ដោយហេតុថា ក្រុមមេធាវីការពារក្តីនៅក្នុងរឿងក្តីលេខ 00១ ជ្រើសរើសមិនចូលរួមដោយសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ដែលក្នុងនោះមានការដាក់សេចក្តីសន្និដ្ឋានទាក់ទងនឹងច្បាប់ដែលត្រូវអនុវត្ត សហចៅក្រមស៊ើបអង្កេត បំពេញកិច្ចមិនត្រឹមត្រូវ នៅពេលគ្រាន់តែយកការរកឃើញអង្គហេតុទាំងឡាយរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *ឌុច* មកអនុវត្តនៅក្នុងដីកាដំណោះស្រាយតែម្តងនោះ។

## ៤.៣ ដីកាដំណោះស្រាយមួយផ្នែកត្រូវចាត់ទុកជាអសាឥតការ

៩៩. ក្រុមមេធាវីការពារក្តីសូមលើកឡើងថា ដីកាដំណោះស្រាយត្រង់ផ្នែកដែលទាក់ទិននឹងការចោទប្រកាន់បញ្ជូនដើមបណ្តឹងឧទ្ធរណ៍ទៅជំនុំជម្រះពីបទល្មើសទាំងឡាយមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ត្រូវចាត់ទុកជាមោឃៈ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅក្នុងកថាខណ្ឌ ១៥៧៤ នៃដីកាដំណោះស្រាយចំពោះបទល្មើសទាំងនេះថា៖

> សហចៅក្រមស៊ើបអង្កេតបានសម្រេចឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដោយទុកលទ្ធភាពឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃអំពីចំណាត់ការបន្តនៃនីតិវិធី ដែលពាក់ព័ន្ធនឹងបទល្មើស ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទាំងនោះ។

១០០. វិធាន ៦៧(២)នៃវិធានផ្ទៃក្នុងចែងថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបញ្ជាក់ [...] អំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត [...] បើពុំនោះ សោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយកំហុសនីតិវិធី"។ ទោះបីជាយ៉ាងនេះក្តី កថាខណ្ឌ ១៥៧៤ ខកខានមិនបានចែងអំពីការកំណត់បទល្មើសដោយផ្អែកលើអង្គហេតុឡើយ។ ដើម្បីនិរាករណ៍តួនាទីរបស់ខ្លួនចោល សហចៅក្រមស៊ើបអង្កេតបញ្ជូនបញ្ហានេះទៅឱ្យអង្គជំនុំជម្រះសាលាដំបូងដោះស្រាយ ដោយខ្លួនមិនសម្រេចដោយខ្លួនឯងឡើយ។

---

105 អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម, សំណុំរឿងលេខ00១, ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២00៩ ឯកសារ E90។

១០១. ដើមបណ្តឹងឧទ្ធរណ៍មានសិទ្ធិទទួលបានព័ត៌មានជាក់លាក់បែបនេះ ដោយសារវាចាំបាច់ដើម្បីឱ្យខ្លួនអាចរៀបចំការការពារខ្លួន និងដើម្បីជៀសវាងហេតុការណ៍ដែលប៉ះពាល់ដល់ខ្លួនជាយថាហេតុ[១០៦]។ ដូច្នេះ មេធាវីការពារក្តីលើក ឡើងថា ដីកាដំណោះស្រាយត្រង់ផ្នែកនេះត្រូវចាត់ទុកជាមោឃៈ ពីព្រោះដីកានេះខកខានមិនបានផ្តល់មូលដ្ឋាន ជាក់លាក់ដល់ដើមបណ្តឹងឧទ្ធរណ៍ ដែល ស.ច.ស យកមូលដ្ឋាននេះមកធ្វើសេចក្តីសម្រេចថា ដើមបណ្តឹង ឧទ្ធរណ៍គួរត្រូវបានជំនុំជម្រះពីបទល្មើសទាំងឡាយដែលបានលើកឡើង។

## V សំណើសុំឱ្យមានសវនាការជាសាធារណៈ

១០២. ក្រុមមេធាវីការពារក្តីសូមជម្រុញដោយក្តីគោរពឱ្យអង្គបុរេជំនុំជម្រះរៀបចំសវនាការជាសាធារណៈដើម្បីដោះស្រាយបញ្ហាយុត្តាធិការ ដែលដើមបណ្តឹងឧទ្ធរណ៍បានលើកឡើង។ បញ្ហាទាំងនេះមានសារៈសំខាន់ចាំបាច់ចំពោះកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ហើយបញ្ហាទាំងនេះទៀតសោតមានលក្ខណៈស្មុគស្មាញខ្លាំងណាស់។ ដោយហេតុថា ក្រុមមេធាវីការពារក្តីត្រូវបានកម្រិតពេលវេលាសម្រាប់ការដាក់សេចក្តីសន្និដ្ឋាននូវទឡ្ហីករណ៍ និងចំនួនទំព័រនៃសារណា បញ្ហាទាំងនេះត្រូវបានលើកឡើងដោយសង្ខេប។ នៅក្នុងសវនាការជាសាធារណៈ ភាគីទាំងឡាយអាចបង្ហាញទឡ្ហីករណ៍របស់ខ្លួនបានពេញលេញ ដែលអាចនឹងឱ្យខ្លួនមានឱកាសឆ្លើយតបចំពោះបញ្ហាចោទនានា ដែលនឹងលេចឡើងដោយជៀសមិនរួច។

## VI សេចក្តីសន្និដ្ឋាន

១០៣. ដូចមានហេតុផលលើកឡើងខាងលើ ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការផ្តន្ទាទោសដើមបណ្តឹងឧទ្ធរណ៍ពីបទល្មើស និងទម្រង់នៃការទទួលខុសត្រូវផ្សេងៗ ដូចបានលើកឡើងខាងលើរួចហើយ។ ហេតុដូច្នេះ ដើមបណ្តឹងឧទ្ធរណ៍ស្នើសុំអង្គបុរេជំនុំជម្រះបដិសេធចោលដីកាដំណោះស្រាយនេះលើចំណុចទាំងឡាយដែលបានលើកឡើងទាំងនោះ ។

---

[106] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajisnik និង Plavsic*, សេចក្តីសម្រេចទាក់ទងនឹង បណ្តឹងបឋមស្តីពីទម្រង់នៃការចោទប្រកាន់, សំណុំរឿងលេខ IT-00-39&40-PT, ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០០០។ សូមមើលផងដែរ Vladimir Tochilovsky, *Jurisprudence of the International Criminal Courts and the European Court of Human Rights* (ឆ្នាំ២០០៨), ទំព័រ៣៣។

១០៤. មេធាវីការពារក្តីសូមស្នើឡើងបន្ថែមទៀតថា ដីកាដំណោះស្រាយនេះពិតជាបានរំលោភទៅលើសិទ្ធិចំពោះការជម្រះក្តីប្រកបដោយយុត្តិធម៌របស់ដើមបណ្តឹងឧទ្ធរណ៍ ហើយអាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើអង្គបុរេជំនុំជម្រះបដិសេធចោលទុកជាអសាឥតការនូវដីកាដំណោះស្រាយនេះដោយឈរលើមូលដ្ឋាននេះ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [stamp: មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA; signature] |